ក

មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

១~ព្រះរាជក្រម

០៩-០១-២០១៤ -ព្រះរាជក្រម នស/រកម/០១១៤/០០៥ ស្ដីពី ការប្រកាសឱ្យប្រើ ច្បាប់ ស្ដីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុនអាឡិច ខបភើរេសិន ៨៤៨

២០-០១-២០១៤ -ព្រះរាជក្រម នស/រកម/០១១៤/០០៦ ស្ដីពី ការប្រកាសឱ្យប្រើ ច្បាប់ ស្ដីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ៨៦៣

២~ព្រះរាជក្រឹត្យ

២៧-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤៣១ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្មដល់លោក **ម៉ូ ប៉ាវហុង** (MO BAOHONG) ជនជាតិចិន សញ្ជាតិចិន កើតនៅខេត្តគ័ងតុង សាធារណរដ្ឋប្រជាមានិតចិន ៨៨២

២៧-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤៣២ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្មដល់លោក **ហ្ស៊ូ ប៊ូ** (ZHOU BO) ជនជាតិចិន សញ្ជាតិចិន កើតនៅ ខេត្តហ្សីជាំងសាធារណរដ្ឋប្រជាមានិតចិន ៨៨៣

២៧-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤៣៣ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្មដល់លោក **លីម ជែហ៊ុន** (LIM JAE HUN) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅខេត្តជៀវលឡាប៊ុកដូ សាធារណរដ្ឋកូរ៉េ ៨៨៤

២៧-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤៣៤ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្មដល់លោក **ចុង សេយ៉ុង** (JUNG SAEYOUNG) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េកើតនៅ ក្រុងជៀងស៊ាងបុកដូ សាធារណរដ្ឋកូរ៉េ ៨៨៥

២៧-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤៣៥ ស្ដីពី ការផ្លាស់លោកជំទាវ **យូ អយ** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំព្រះរាជាណាចក្រថៃ ចូលប្រទេសវិញ ដោយត្រូវចប់អាណត្តិបេសកកម្ម ៨៨៦

២៧-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤៣៦ ស្ដីពី ការតែងតាំងលោកជំទាវ **អ៊ិត សោភា** ជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំព្រះរាជាណាចក្រថៃ ៨៨៧

៣០-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤៣៧ ស្ដីពី ការផ្ទេរ និងតែងតាំងឯកឧត្តម ស្រី ឈឿរី ពីនាយកព្រះរាជលេខាធិការដ្ឋានព្រះមហាក្សត្រ ជានាយកព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ មានឋានៈស្មើ ទេសរដ្ឋមន្ត្រី ៨៨៨

៣០-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤៤០ ស្ដីពី ការតែងតាំងទីប្រឹក្សាផ្ទាល់ និងជំនួយការលោកជំទាវ ឃួន សុដារី អនុប្រធានទី ២ នៃរដ្ឋសភា ក្នុងនីតិកាលទី ៥ ចំនួន ០៧ រូប ៨៨៩

៣០-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤៤១ ស្ដីពី ការតែងតាំងឯកឧត្តម តៃ គេតនិន ជាអគ្គនាយកសេវា និងបច្ចេកទេស នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ៨៩១

៣០-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤៤២ ស្ដីពី ការដាក់ឱ្យចូលនិវត្តន៍ឯកឧត្តម ឈៀម ជូឡុង ៨៩២

៣១-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤៤៣ ស្ដីពី ការតែងតាំងឯកឧត្តម គីម សុខុន ជាអនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ៨៩៣

៣១-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤៤៤ ស្ដីពី ការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៨៩៤

៣១-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤៤៥ ស្ដីពី ការបង្កើត ខេត្តត្បូងឃ្មុំ ៨៩៨

០២-០១-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០១១៤/០០១ ស្ដីពី ការតែងតាំងឯកឧត្តម ថៃ ហ្វា ជាទីប្រឹក្សានៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានឋានៈស្មើ រដ្ឋលេខាធិការ ៩០០

០២-០១-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០១១៤/០០២ ស្ដីពី ការតម្លើងឋានន្តរស័ក្តិជូននាយនគរបាលថ្នាក់ឧត្តមសេនីយ៍ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ក្រសួងមហាផ្ទៃ ចំនួន ២៨ រូប ៩០១

II~រាជរដ្ឋាភិបាល

អនុក្រឹត្យ

០៦-០១-២០១៤-អនុក្រឹត្យលេខ ០៨ អនក្រ.បក ស្ដីពី ការកាត់ដីទំហំ ២.៦០៥,០០២២ ហិកតា នៅស្រុកទឹកឈូ ខេត្តកំពត ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៩២៧ គ្រួសារ និងរក្សាទុកមួយ ចំណែកជាដីសាធារណៈរបស់រដ្ឋ ៩០៣

០៦-០១-២០១៤-អនុក្រឹត្យលេខ ០៩ អនក្រ.បក ស្ដីពី ការកាត់ដីសរុបទំហំ ៤.៤៨៨,២២ ហិកតា នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ក្នុងនោះកាត់ចេញពីដីព្រៃសម្បទានសំរោងវូដ និងកាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកសម្រាប់ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងការផ្ដល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី ៩០៨

០៦-០១-២០១៤-អនុក្រឹត្យលេខ ១០ អនក្រ.បក ស្ដីពី ការកាត់ដីសរុបទំហំ ៤.០០៥,៩២ ហិកតា នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ក្នុងនោះកាត់ចេញពីដីព្រៃសម្បទានរបស់ក្រុមហ៊ុនសំរោងរ៉ូដ កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន សំរោងរ៉ូដ និងកាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកសម្រាប់ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងការផ្ដល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី ៩១៤

០៦-០១-២០១៤-អនុក្រឹត្យលេខ ១១ អនក្រ.បក ស្ដីពី ការកាត់ដីទំហំ ៤.៨០០,៦៦ ហិកតា នៅស្រុកក្រគរ ខេត្តពោធិ៍សាត់ ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ភាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋព្រមទាំងការផ្ដល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី ៩១៨

១០-០១-២០១៤-អនុក្រឹត្យលេខ ២៨ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៩២៤

១០-០១-២០១៤-អនុក្រឹត្យលេខ ២៩ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៩២៧

១០-០១-២០១៤-អនុក្រឹត្យលេខ ៣០ អនក្រ.តត ស្ដីពី ការតែងតាំងមុខតំណែងនាយនគរបាលជាន់ខ្ពស់ ៩៣២

១៣-០១-២០១៤-អនុក្រឹត្យលេខ ៣១ អនក្រ.តត ស្ដីពី ការជូនមេដាយសុវត្ថារា ៩៣៣

១៣-០១-២០១៤-អនុក្រឹត្យលេខ ៣២ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៩៣៤

១៣-០១-២០១៤-អនុក្រឹត្យលេខ ៣៣ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៩៣៦

១៣-០១-២០១៤-អនុក្រឹត្យលេខ ៣៤ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៩៣៧

១៣-០១-២០១៤-អនុក្រឹត្យលេខ ៣៥ អនក្រ.តត ស្ដីពី ការជូនមេដាយសហមេត្រី ៩៣៨

១៣-០១-២០១៤-អនុក្រឹត្យលេខ ៣៦ អនក្រ.តត ស្ដីពី ការជូនមេដាយសហមេត្រី ៩៤០

១៣-០១-២០១៤-អនុក្រឹត្យលេខ ៣៧ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៩៤២

១៣-០១-២០១៤-អនុក្រឹត្យលេខ ៣៨ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៩៤៥

III-ការងារបណ្ដាក្រសួង

ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៥-១២-២០១៣-ប្រកាសលេខ ១៥០២ សហវ.ប្រក ស្ដីពី ការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យរបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ៩៤៩

ព្រះរាជក្រម

នស/រកម/០១១៤/០០៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឲ្យក្រុមហ៊ុនអាឡិច ឧបកើរសិន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៣ នាសម័យប្រជុំលើកទី៤ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើការធានានូវទូទាត់របស់ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឲ្យក្រុមហ៊ុនអាឡិច ខបតើរេសិន

មាត្រា ១.-

អនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ចំពោះក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងអគ្គិសនីកម្ពុជា ឲ្យក្រុមហ៊ុនអាឡិច ខបតើរេសិន ក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងអនុវត្តគម្រោង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនអាឡិច ខបតើរេសិន និងកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី រវាងអគ្គិសនីកម្ពុជា និង ក្រុមហ៊ុនអាឡិច ខបតើរេសិន ដែលបានចុះហត្ថលេខា នៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១៣។ ការធានានេះមានអត្ថបទទាំងស្រុង ដែលបានចុះហត្ថលេខា កាលពីថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០១៣ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តកាលនីតិវិធី ដើម្បីអនុវត្តលិខិតធានាទូទាត់នេះ ។

មាត្រា ៣.-

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៤

នស/រកម/០១១៤/០២៦

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

អូន ព័ន្ធមុនីរ័ត្ន

លេខ: ៥១ ស.ណ

សំណៅដែលមានតម្លៃជាការចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ២០១៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧២ សរក

សិទ្ធិប្រទាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/១២១២/០១០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្ដីពីវិសោធនកម្ម នៃច្បាប់ស្ដីពីវិនិយោគ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣
- បានឃើញព្រះរាជក្រម លេខ នស/រកម/១០០៧/០២៧ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសម្បទាន
- បានឃើញអនុក្រឹត្យ លេខ ១១១ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៥ ស្ដីពីការអនុវត្តច្បាប់ ស្ដីពីវិសោធនកម្ម នៃច្បាប់ស្ដីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមការសម្រេចរបស់គណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៣

រាជរដ្ឋាភិបាល

ប្រគល់សិទ្ធិពេញសមត្ថភាព ជូនឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងអនុវត្តគម្រោង Implementation Agreement (IA), និងលើលិខិតធានាទូទាត់ របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា Governmental Guarantee of Payment ដោយអគ្គិសនីកម្ពុជា (EDC) និង/ឬ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ទៅឱ្យក្រុមហ៊ុន Alex Corporation Co., Ltd. សម្រាប់គម្រោងវិនិយោគសាងសង់ខ្សែបណ្ដាញបញ្ជូនអគ្គិសនី តង់ស្យុង ២៣០ គីឡូវ៉ុល ប្រវែង ១៩៨ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ ទៅខេត្តព្រះសីហនុ ។

ក្នុងករណីដែលឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** មានធុរៈជាយថាហេតុ ឯកឧត្តមអាចផ្ទេរសិទ្ធិនេះបាន ។

ដើម្បីជាសក្ខីភាព នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដោយមានសិទ្ធិពេញលេញតាមអំណាចច្បាប់ បានចុះហត្ថលេខាខាងក្រោម លើសិទ្ធិប្រទាននេះ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..០០១......សហវ.....

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លិខិតធានារបស់រាជរដ្ឋាភិបាលលើការទូទាត់

ជូនចំពោះ ៖ **លោក** Lau Yao Zhong
Alex Corporation Co., Ltd.
អាសយដ្ឋាន៖ លេខ CE4, ផ្លូវលេខ ២៦៥, សង្កាត់ទឹកល្អក់៣, ខណ្ឌទួលគោក, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
ទូរសារ ៖ ៨៥៥ ២៣ ៨៦៦ ៦៦៦

យោង ៖

(ក) សិទ្ធិប្រទាន លេខ ៧២ សប្រទ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា (ឧបសម្ព័ន្ធ១) ។

(ខ) កិច្ចព្រមព្រៀងអនុវត្តគម្រោង (IA) ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣ ដែលបានចុះហត្ថលេខារវាងរាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (ឧ.រ.ថ) និងក្រុមហ៊ុន អាឡិច ខបកើរេសិន (Alex Corporation Co., Ltd.) (ក្រុមហ៊ុន) ។

(គ) អគ្គិសនីកម្ពុជា ជាសហគ្រាសរដ្ឋ មានការទទួលខុសត្រូវមានកំណត់ បានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៦/១០ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ១៩៩៦ មានការិយាល័យធំរបស់ខ្លួន តាំងនៅផ្លូវលេខ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា រាប់បញ្ចូលទាំងអ្នកបន្តវេន និងអ្នកដែលបានអនុញ្ញាតឱ្យទទួលសិទ្ធិ (អ.ក), បានចុះកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី (PTA) ជាមួយក្រុមហ៊ុន ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣ ។

(ឃ) រាជរដ្ឋាភិបាលកម្ពុជា យល់ព្រមផ្តល់ ៖ (១)-ការធានាលើការទូទាត់ថ្លៃបញ្ជូនអគ្គិសនី សម្រាប់ការប្រើប្រាស់គម្រោង ១០០% (មួយរយភាគរយ) ក្នុងករណីដែល អ.ក មិនធ្វើការទូទាត់ និង (២)-ការធានាលើការទូទាត់បញ្ចប់កិច្ចព្រមព្រៀង ស្របតាមកិច្ចព្រមព្រៀង PTA និង/ឬ IA និងក្នុងករណីដែលក្រុមហ៊ុន មិនអាចដំណើរការគម្រោងបាន ដែលបណ្តាលមកពីព្រឹត្តិការណ៍ប្រធានសក្តិនយោបាយ ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

(ង) តាមការតម្រូវក្នុងប្រការ ៤.៨ នៃកិច្ចព្រមព្រៀងអនុវត្តគម្រោង រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ស.ហ.វ) ជំនួសមុខឱ្យរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា (អ្នកធានា) បានយល់ព្រមចុះហត្ថលេខា លើលិខិតធានាលើការទូទាត់ ដែលជាកាតព្វកិច្ចរបស់ អ.ក ឬ ឧ.រ.ថ ស្របតាម PTA និង IA ។

ដូច្នេះ យើងខ្ញុំសូមធានា ថា ៖

១. អ្នកធានាសូមធានា និងសន្យា ដោយគ្មានលក្ខខណ្ឌ និងដោយគ្មានការបដិសេធ ទូទាត់ឱ្យក្រុមហ៊ុន នូវចំនួនទឹកប្រាក់ណាមួយ និងទាំងអស់ ដែលត្រូវបង់ និងជំពាក់ដោយ ឧ.រ.ថ ឬ អ.ក ឱ្យក្រុមហ៊ុន ក្រោមកិច្ចព្រមព្រៀង IA ឬ PTA ដែល ឧ.រ.ថ ឬ អ.ក ខកខានពុំបានទូទាត់ អនុលោមតាមអាណត្តិ នៃ IA ឬ PTA (លិខិតធានា) ។

២. លិខិតធានានេះ ត្រូវជាការធានាបន្តរហូត និងឱ្យបានសមស្រប និងត្រូវទូទាត់តុល្យការទឹកប្រាក់ ដែលត្រូវបង់ឱ្យក្រុមហ៊ុនគ្រប់ពេល ដោយ ឧ.រ.ថ ឬ អ.ក ក្រោមកិច្ចព្រមព្រៀង IA ឬ PTA ទោះជាមានលិខិតជូនដំណឹងណាមួយ ស្តីពីការបញ្ចប់កិច្ចព្រមព្រៀង ឬការរំលាយ ឬអសមត្ថភាព ឬការផ្លាស់ប្តូរណាមួយ ក្នុងព្រះរាជក្រឹត្យពាក់ព័ន្ធនឹង ឧ.រ.ថ ឬ អ.ក ឬក្នុងនាម ឬរបៀប ឬការទូទាត់គណនីណាមួយ ឬបញ្ហាផ្សេងទៀតក៏ដោយ ។

៣. មុនពេលឈានដល់ការអនុវត្តលិខិតធានានេះ និងធ្វើសំណើសុំការទូទាត់ពីអ្នកធានា ក្រុមហ៊ុនត្រូវធ្វើសំណើជាលាយលក្ខណ៍អក្សរ ស្នើសុំការទូទាត់ពី ឧ.រ.ថ ឬ អ.ក ។ ក្រោយរយៈពេលហុកសិប (៦០) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃវិក្កយបត្រ ដូចមានចែងក្នុងប្រការ ១១.១ នៃ PTA ឬសំណើសុំទូទាត់ណាមួយពីក្រុមហ៊ុន ទៅ ឧ.រ.ថ ត្រូវបានទទួលដោយ អ.ក ឬ ឧ.រ.ថ ក្រុមហ៊ុនអាចជូនដំណឹងទៅអ្នកធានា ជាលាយលក្ខណ៍អក្សរថា ការទូទាត់ ដោយ ឧ.រ.ថ ឬ អ.ក បានហួសកាលកំណត់ និងលើកសំណើសុំទូទាត់ពីអ្នកធានា ស្របតាមលិខិតធានានេះ ហើយអ្នកធានា ត្រូវធ្វើការទូទាត់ ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ ។ ការយឺតយ៉ាវក្នុងការទូទាត់ របស់អ្នកធានា ក្រោមលិខិតធានានេះ ត្រូវគិតការប្រាក់តាមអត្រាការប្រាក់ប្រចាំឆ្នាំ LIBOR បូក ៣% (បីភាគរយ) ។ ពុំមានសំណើណាមួយ ដែលធ្វើឡើងដោយក្រុមហ៊ុន ស្របតាមលិខិតធានានេះ ដែលប៉ះពាល់ ឬជំទាស់សិទ្ធិ របស់ក្រុមហ៊ុន ក្នុងការធ្វើសំណើបន្ថែម ឬផ្សេងទៀត ចំពោះវិក្កយបត្រ ដែលមិនទាន់ទូទាត់ផ្សេងទៀតឡើយ ។

ទឹកប្រាក់ទាំងអស់ ដែលអ្នកធានាត្រូវទូទាត់តាមលិខិតធានានេះ ត្រូវបង់ទាំងអស់ចូលក្នុងគណនីធនាគារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលកំណត់ដោយក្រុមហ៊ុន ជាប្រាក់ដុល្លារអាមេរិកឱ្យក្រុមហ៊ុន ។

៤. រាល់សំណើសុំទូទាត់ ដែលបានធ្វើឡើងតាមលិខិតធានានេះ ត្រូវធ្វើឡើងតាមរយៈអ្នករត់សំបុត្រ ឬដោយផ្ទាល់ ដោយមន្ត្រីទទួលបានការអនុញ្ញាតស្របច្បាប់របស់ក្រុមហ៊ុន នៅការិយាល័យរបស់អ្នកធានា និងត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ ដែលមានចុះហត្ថលេខាដោយមន្ត្រី ដែលបានទទួលការអនុញ្ញាតស្របច្បាប់របស់ក្រុមហ៊ុន ដោយគ្មានកាតព្វកិច្ចណាផ្សេងទៀត បញ្ជាក់ថា ៖

"យើងខ្ញុំ សូមបញ្ជាក់ថា ៖

(១). ក្រុមហ៊ុន អាឡិច ខបភើរេសិន (ក្រុមហ៊ុន) បានធ្វើសំណើសុំទូទាត់ ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អ្នកធានា) នូវចំនួនទឹកប្រាក់........... {បញ្ចូលទឹកប្រាក់} ដុល្លារអាមេរិក ស្របតាមចំណុចទី១ នៃលិខិតធានារបស់រាជរដ្ឋាភិបាល លើការទូទាត់ ចុះថ្ងៃទី.......ខែ......... ឆ្នាំ២០១៣ រវាង អ្នកធានា និង ក្រុមហ៊ុន ។

(២). ចំនួនទឹកប្រាក់ខាងលើ គឺដល់កាលកំណត់ និងត្រូវទូទាត់ដោយ អ.ក ឬ ឧ.រ.ថ ស្របតាម PTA/IA រវាងក្រុមហ៊ុន និង អ.ក ឬ ឧ.រ.ថ និងពុំមានផ្នែកណាមួយនៃចំនួនទឹកប្រាក់ដែលបានបញ្ជាក់ខាងលើ ជាកម្មវត្ថុនៃវិវាទ រវាង អ.ក ឬ ឧ.រ.ថ និងក្រុមហ៊ុន នោះទេ ។

(៣). សំណើសុំទូទាត់ពី ឧ.រ.ថ ឬ អ.ក ជាលាយលក្ខណ៍អក្សរ បានផ្ញើរួចហើយ ។

(៤). ចំនួនទឹកប្រាក់នេះ នៅពុំទាន់បានទូទាត់ដោយ ឧ.រ.ថ ឬ អ.ក រហូតដល់ថ្ងៃនេះ។

៥. អ្នកធានាសូមអះអាង និងធានា នៅថ្ងៃនេះថា ៖

- អ្នកធានាមានសិទ្ធិពេញសមត្ថភាព និងការអនុញ្ញាតស្របច្បាប់ ក្នុងការទទួលកាតព្វកិច្ច ការចុះហត្ថលេខា ការប្រគល់ ព្រមទាំងប្រតិបត្តិ និងអង្កេតអាណត្តិ និងបញ្ញត្តិនានា នៃលិខិតធានានេះ ។
- លិខិតធានានេះ ជាកាតព្វកិច្ចរបស់អ្នកធានា ស្របច្បាប់ មានសុពលភាព ប្រសិទ្ធភាព និងជាចំណងផ្លូវច្បាប់ អនុលោមតាមអាណត្តិ របស់លិខិតធានានេះ ។
- រាល់សកម្មភាពចាំបាច់ត្រូវបានអនុវត្ត និងរាល់ការយល់ព្រមដែលតម្រូវឱ្យមាន ត្រូវបានទទួលរួចហើយ ក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីផ្តល់សិទ្ធិក្នុងការចុះហត្ថលេខា ការប្រគល់ និងការប្រតិបត្តិលិខិតធានានេះ ។
- កាតព្វកិច្ច និងការព្រមព្រៀងនានា របស់អ្នកធានា ក្នុងលិខិតធានានេះ ជាកាតព្វកិច្ចដោយគ្មានលក្ខខណ្ឌរបស់អ្នកធានា ដែលក្នុងការអនុវត្តកាតព្វកិច្ចទាំងនេះ ជំនឿទុកចិត្ត និងកិត្តិយសរបស់អ្នកធានា ត្រូវបានប្រកាន់ខ្ជាប់ ។
- អ្នកធានា បានយល់ព្រមដោយគ្មានលក្ខខណ្ឌ និងដោយគ្មានការបដិសេធថា ការចុះហត្ថលេខា ការប្រគល់ និងការអនុវត្តដោយអ្នកធានា តាមលិខិតធានានេះ គឺជាសកម្មភាពពាណិជ្ជកម្ម មិនមែនជាសកម្មភាពសាធារណៈ ឬជាសកម្មភាពរដ្ឋាភិបាលទេ ហើយលិខិតធានានេះ គឺជា កាតព្វកិច្ចដោយផ្ទាល់ ដោយគ្មានលក្ខខណ្ឌ និងដោយមិនអាចបដិសេធបានឡើយ ។
- ប្រសិនបើមានបណ្តឹងណាមួយ ចំពោះអ្នកធានា ឬចំពោះទ្រព្យសម្បត្តិរបស់អ្នកធានា ក្នុងយុត្តាធិការណាមួយ ដែលទាក់ទងនឹងកិច្ចព្រមព្រៀងនេះ ពុំមានអភ័យឯកសិទ្ធិណាមួយពីបណ្តឹងនោះ ត្រូវបានទាមទារដោយ ឬតាងនាមរបស់ខ្លួន ឬទាក់ទងទៀតនឹងទ្រព្យសម្បត្តិរបស់ខ្លួន ដែលមានបច្ចុប្បន្ន ឬអាចទទួលបាននាពេលអនាគត ។

៦. លិខិតធានានេះ ត្រូវមានសុពលភាព និងប្រសិទ្ធភាពចាប់ពីកាលបរិច្ឆេទសាងសង់ (Construction Commencement Date) រហូតដល់ចប់អាណត្តិ នៃ IA ឬ PTA និងត្រូវបន្តពេលយូរតទៅទៀត តាមចំនួនទឹកប្រាក់ណាមួយ ដែល អ.ក នៅជំពាក់ក្រុមហ៊ុន ទាក់ទងនឹងអាណត្តិនេះ ឬនៅពុំទាន់ទូទាត់ ។ រីឯការធានាលើការទូទាត់លើថ្លៃបញ្ជូនអគ្គិសនី ក្នុងករណីដែល អ.ក មិនធ្វើការទូទាត់សម្រាប់ការប្រើប្រាស់សមត្ថភាពគម្រោង ត្រូវមានសុពលភាពចាប់ពីថ្ងៃដែលគម្រោងដំណើរការអាជីវកម្ម (Commercial Operation Date) ។

៧. គ្មានការខកខាន ឬការយឺតយ៉ាវណាមួយ ដោយក្រុមហ៊ុន ក្នុងការអនុវត្តសិទ្ធិ ឬការដោះស្រាយក្រោមលិខិតធានានេះ ត្រូវបានចាត់ទុកជាការបោះបង់សិទ្ធិ ឬការដោះស្រាយនោះឡើយ ។ គ្មានការអនុវត្តសិទ្ធិ ឬការដោះស្រាយតែមួយ ឬតែមួយផ្នែក រារាំងការអនុវត្តបន្ថែម នូវសិទ្ធិ ឬការដោះស្រាយណាមួយផ្សេងទៀតឡើយ ។ គ្មានការបដិសេធណាមួយរបស់ក្រុមហ៊ុន មានប្រសិទ្ធភាពទេ លើកលែងតែការបដិសេធនោះ ធ្វើឡើងជាលាយលក្ខណ៍អក្សរ ។ សិទ្ធិ និងការដោះស្រាយនានា ដែលបានផ្តល់ឱ្យក្រុមហ៊ុន ដោយលិខិតធានានេះ គឺជាការផ្តល់បន្ថែម និងមិនលើកលែងសិទ្ធិ និងការដោះស្រាយណាមួយ ដែលត្រូវបានផ្តល់ដោយច្បាប់ឡើយ ។

៨. រាល់លិខិតជូនដំណឹង ឬលិខិតឆ្លើយឆ្លងផ្សេងៗទៀត (ដែលត្រូវហៅកាត់រួមគ្នាថា "លិខិតជូនដំណឹង") ដែលត្រូវផ្តល់ ឬធ្វើឡើងស្របតាមលិខិតធានានេះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវដាក់អាសយដ្ឋានបញ្ជូនទៅបុគ្គល ដូចមានបញ្ជាក់ខាងក្រោម ដោយត្រូវប្រគល់ផ្ទាល់ដៃ ឬតាមអ្នករត់សំបុត្រ ។ រាល់លិខិតជូនដំណឹង ត្រូវបានចាត់ទុកថា បានប្រគល់ ៖

(ក). ពេលបានប្រគល់ផ្ទាល់ដៃ, ឬ

(ខ). នៅពេលប្រគល់ ដោយមានការកត់ត្រាត្រឹមត្រូវ និងមានការបានទទួល ដោយអ្នកផ្ញើឯកសារដែលមានការទទួលស្គាល់ជាអន្តរជាតិ បញ្ជូនទៅភាគីទទួល នៅអាសយដ្ឋានដូចខាងក្រោម (ឬក៏អាសយដ្ឋានដទៃទៀត ដែលភាគីនោះ អាចបញ្ជាក់តាមរយៈលិខិតជូនដំណឹង ឱ្យទៅភាគីប្រគល់លិខិត នៅអាសយដ្ឋាន ឬលេខទូរសារ ចែងខាងក្រោម) ៖

សម្រាប់ អ្នកធានា ៖

ជូនចំពោះ	៖ ឯកឧត្តម រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
អាសយដ្ឋាន	៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្លូវលេខ៩២, សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
ទូរសារលេខ	៖ +៨៥៥ ២៣ ៤២៧ ៧៩៨

សម្រាប់ ក្រុមហ៊ុន ៖

អាសយដ្ឋាន	៖ លេខ CE4, ផ្លូវលេខ ២៦៥, សង្កាត់ទឹកល្អក់៣, ខណ្ឌទួលគោក, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

ជូនចំពោះ ៖ ប្រធានក្រុមហ៊ុន
ទូរសារលេខ ៖ +៨៥៥ ២៣ ៨៦៦ ៦៦៦

ឬក៏អាសយដ្ឋានផ្សេងទៀត ដែលភាគីណាមួយ អាចជូនដំណឹងឱ្យភាគីមួយទៀត ។

៩. អ្នកជានាមិនត្រូវប្រគល់ ឬផ្ទេរសិទ្ធិ ឬកាតព្វកិច្ចទាំងអស់ ឬមួយផ្នែករបស់ខ្លួន ក្រោមលិខិតជានានេះ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុន ពីក្រុមហ៊ុនឡើយ ហើយក្រុមហ៊ុនមិនត្រូវប្រគល់ ឬផ្ទេរសិទ្ធិ ឬកាតព្វកិច្ចទាំងអស់ ឬមួយផ្នែករបស់ខ្លួន ក្រោមលិខិតជានានេះ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុន ពីអ្នកជានាឡើយ ។ ថ្វីបើមានបញ្ញត្តិក្នុងវាក្យខណ្ឌមុននេះក្តី សម្រាប់គោលបំណងអភិវឌ្ឍន៍ ឬការផ្តល់ហិរញ្ញប្បទានអចិន្ត្រៃយ៍ដល់គម្រោង ក្រុមហ៊ុនអាចប្រគល់សិទ្ធិ ឬបង្កើតការធានាផលប្រយោជន៍ ចំពោះសិទ្ធិ និងផលប្រយោជន៍ ក្នុង និងចំពោះលិខិតជានានេះ សម្រាប់ជាប្រយោជន៍ដល់អ្នកឱ្យខ្ចីប្រាក់ ។ លិខិតជានានេះ ត្រូវជាចំណងផ្លូវច្បាប់ និងមានប្រសិទ្ធភាព ជាប្រយោជន៍ដល់អ្នកជានា និងក្រុមហ៊ុន ព្រមទាំងអ្នកបន្តវេន និងអ្នកទទួលសិទ្ធិស្របច្បាប់ របស់ភាគីនីមួយៗ ។

១០. សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកជានា និងក្រុមហ៊ុន ក្រោម ឬអនុលោមតាមលិខិតជានានេះ ត្រូវបានគ្រប់គ្រងដោយ និងបកស្រាយ តាមច្បាប់នៃប្រទេសអង់គ្លេស ដែលនឹងត្រូវជាច្បាប់គ្រប់គ្រងមជ្ឈត្តវិនិច្ឆ័យផងដែរ ។

១១. ប្រសិនបើមានវិវាទ ឬការខ្វែងគំនិតណាមួយកើតឡើង តាមរូបភាពណាក៏ដោយ ឬពាក់ព័ន្ធនឹងលិខិតជានានេះ ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ បន្ទាប់ពីភាគីមួយ បានទទួលសេចក្តីជូនដំណឹងពីភាគីមួយទៀត ស្តីពីការកើតឡើងនៃវិវាទ អ្នកជានា និងក្រុមហ៊ុន ត្រូវដោះស្រាយវិវាទនោះ តាមរយៈការពិភាក្សាជាមិត្តភាព ។ ប្រសិនបើមិនអាចដោះស្រាយបានតាមរយៈការពិភាក្សាជាមិត្តភាពទេ ត្រូវបញ្ជូនវិវាទនោះ ទៅមជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរ ដើម្បីដោះស្រាយស្របទៅតាមវិធាន នៃមជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរនោះ ។ ប្រសិនបើមានភាពមិនស្របគ្នាដោយអន្លើ រវាងបញ្ញត្តិនេះ និងវិធានរបស់មជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរ បញ្ញត្តិនេះត្រូវមានប្រសិទ្ធភាព ។ សេចក្តីសម្រេច ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយគឺជាសេចក្តីសម្រេចស្ថាពរ ជាសេចក្តីសន្និដ្ឋាន និងជាចំណងផ្លូវច្បាប់ទៅលើអ្នកជានា និងក្រុមហ៊ុន និងអាចយកមកអនុវត្ត នៅក្នុងតុលាការកម្ពុជាណាមួយ ដែលមានយុត្តាធិការ ធ្វើឱ្យសេចក្តីសម្រេចនោះ អនុវត្តបាន ។ ភាគីទាំងពីរត្រូវទទួលយក និងអនុវត្តសេចក្តីសម្រេចនោះ ហើយភាគីនីមួយៗ ត្រូវទម្លាក់ចោលដោយឥតលក្ខខណ្ឌ នូវសិទ្ធិណាមួយដែលគេអាចមាន ដើម្បីតវ៉ាអំពីសុពលភាពនៃសេចក្តីសម្រេចនោះ ឬយុត្តាធិការនៃតុលាការមជ្ឈត្តវិនិច្ឆ័យនោះ ដើម្បីធ្វើសច្ចការឯកសារយោងណាមួយ ទៅមជ្ឈត្តវិនិច្ឆ័យ ដែលលិខិតជានានេះមានប្រសិទ្ធភាពអនុវត្ត ។ រាល់ការទូទាត់តាមសេចក្តីសម្រេចរបស់មជ្ឈត្តវិនិច្ឆ័យ ត្រូវធ្វើជាប្រាក់ដុល្លារអាមេរិក ។ ចំណាយលើមជ្ឈត្តវិនិច្ឆ័យ ត្រូវទូទាត់ដោយភាគីដែលចាញ់ក្តី លើកលែងតែមានការកំណត់ផ្សេងពីនេះ ដោយតុលាការមជ្ឈត្តវិនិច្ឆ័យនោះ ។ ភាគីដែលទទួលខុសត្រូវទូទាត់តាមសេចក្តីសម្រេចរបស់មជ្ឈត្តវិនិច្ឆ័យ ត្រូវបង់ការប្រាក់តាមអត្រា LIBOR បូក ៣%

(បីភាគរយ) ទៅឱ្យភាគីម្ខាងទៀត នៅពេលទទួលសេចក្តីសម្រេចពីមជ្ឈត្តវិនិច្ឆ័យនោះ ដោយគិតចាប់ពីកាលបរិច្ឆេទត្រូវទូទាត់ រហូតដល់ថ្ងៃទូទាត់រួច ។

១២. ពាក្យសរសេរជាអក្សរធំ ដែលបានប្រើ ប៉ុន្តែពុំមានកំណត់ន័យក្នុងលិខិតជានានេះ ត្រូវមានន័យដូចបានកំណត់ក្នុងកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី ។

១៣. ប្រសិនបើបញ្ញត្តិណាមួយ ឬច្រើន ក្នុងលិខិតជានានេះ ត្រូវបានរកឃើញថា គ្មានសុពលភាព ខុសច្បាប់ ឬមិនអាចអនុវត្តបាន បញ្ញត្តិទាំងនោះ ត្រូវរក្សាតម្លៃដែលអនុញ្ញាតដោយច្បាប់ ហើយភាពគ្មានសុពលភាព ភាពខុសច្បាប់ ឬភាពមិនអាចអនុវត្តបានទាំងនោះ ពុំមានឥទ្ធិពលដល់សុពលភាព នៃបញ្ញត្តិផ្សេងទៀត នៃលិខិតជានានេះឡើយ ។

តាមការឯកភាពគ្នាទៅវិញទៅមក គ្មានការកាត់កង ការទាមទារទៅវិញទៅមក ការបន្ធូរបន្ថយ ឬការបន្ថយកាតព្វកិច្ចណាមួយ ដែលអ្នកជានាមាន ឬអាចមានចំពោះក្រុមហ៊ុន ត្រូវតែមានសម្រាប់អ្នកជានា ដើម្បីតតាំងជាមួយក្រុមហ៊ុន ទាក់ទងនឹងកាតព្វកិច្ចណាមួយ របស់អ្នកជានាចំពោះក្រុមហ៊ុន ក្រោមលិខិតជានានេះឡើយ ។

១៤. លិខិតជានានេះ ត្រូវផុតសុពលភាពនៅពេលបញ្ចប់ IA និង PTA ប្រសិនបើគ្មានការទាមទារ ហើយនៅរក្សាការជានានេះដដែល ក្នុងករណីមានសំណើសុំការទូទាត់ជាលាយលក្ខណ៍អក្សរណាមួយ ពីលោក បញ្ជូនមកយើងខ្ញុំ ស្របតាមលិខិតជានានេះ ដែលត្រូវតែទទួលបានដោយយើងខ្ញុំ មុនពេលនោះ ។

១៥. លិខិតជានានេះ នឹងចូលជាធរមាន និងមានប្រសិទ្ធភាពអនុវត្ត បន្ទាប់ពីទទួលបានការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ នៃព្រះរាជាណាចក្រកម្ពុជា ។

សូមលោកប្រធាន មេត្តាទទួលនូវការរាប់អាន ពីខ្ញុំ ។

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

...ត. អូន ព័ន្ធមុនីរ័ត្ន

ចម្លងជូន៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អគ្គិសនីកម្ពុជា
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia

រាជរដ្ឋាភិបាល
Royal Government

ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

N. 72 DFI

Phnom Penh, November 5, 2013

DELEGATION OF FULL POWERS

- Seen the Constitution of the Kingdom of Cambodia
- Seen the Royal Decree NS/RKT/0913/903 dated 24 of September 2013 on the nomination of the Royal Government of Cambodia
- Seen the Royal Kram 02/NS/94 dated 20 of July 1994 promulgating the Law on the Organization and Functioning of the Council of Ministers
- Seen the Royal Kram NS/RKM/1212/010 dated 26 of December 2012 promulgating the Law on Finance for Management of Fiscal Year 2013
- Seen the Royal Kram 03/NS/94 dated 05 0f August 1994 promulgating the Law on Investment of Kingdom of Cambodia and the Law on Amendment of Law on Investment of Kingdom of Cambodia promulgated by the Royal Kram NS/RKM/0303/009 dated 24 of March 2003
- Seen the Royal Kram NS/RKM/1007/027 dated 19 0f October 2007 promulgating the Law on Concessions
- Seen Sub-decree 111 អនក្រ.បក dated 27 of September 2005 on Implementation of the Law on Amendment of Law on Investment of Kingdom of Cambodia
- Referring to the decision of Council of Ministers in its plenary session on 25 October 2013

THE ROYAL GOVERNMENT OF CAMBODIA

Delegates herewith to H.E. MR. AUN PORNMONIROTH, Minister of Economy and Finance, full power to sign the Implementation Agreement (IA), and the Governmental Guarantee of Payment by the EDC and/or MIME to ALEX CORPORATION CO., LTD. for the Development of 230kV Phnom Penh-Preah Sihanouk Transmission System Project.

These powers include the powers of delegation.

In witness whereof the undersigned, the Prime Minister of the Kingdom of Cambodia with full powers duly entrusted to him, has signed this delegation of full powers.

Prime Minister

Samdech Akka Moha Sena Padei Techo HUN SEN

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
№ 001 MEF/..............

Phnom Penh, November 13 , 2013

GOVERNMENT GUARANTEE OF PAYMENTS

Mr. Lau Yao Zhong,
Alex Corporation Co., Ltd.
Address : No. CE4, Street 265, Teuk Laak 3 commune, Toul Kok district, Phnom Penh, Kingdom of Cambodia.
Facsimile : +855 23 866 666

Dear Sir,

We refer to:

(A) Delegation of Full Power No. 72 D.F.P. dated 5 November 2013 by Samdech Akka Moha Sena Padei Techo HUN SEN, Prime Minister of the Kingdom of Cambodia. (Attachment 1).

(B) The Implementation Agreement ("IA") dated 12 November 2013, entered between the Royal Government of Cambodia ("RGC") represented by Senior Minister, Minister of Ministry of Industry, Mines and Energy ("MIME") and Alex Corporation Co., Ltd. (the "Company").

(C) ELECTRICITÉ DU CAMBODGE, a wholly state-owned limited liability enterprise incorporated by Royal Decree No. CHS/RD/0396/10 of the RGC dated 9 March 1996, with its principal office located at Street 19, Wat Phnom, Daun Penh District, Phnom Penh, in the Kingdom of Cambodia, including its successors and permitted assignees ("EDC") has entered into a Power Transmission Agreement ("PTA") with the Company dated 12 November 2013.

(D) The Royal Government of Cambodia agreed to provide: (i) a guarantee on the payment for PTA charges for 100% of the Project in the event of non-payment by EDC, and (ii) a guarantee on the payment on the termination in accordance with the PTA and/or IA and in the event that the Company is unable to operate the Project arising from the Political Force Majeure Events.

(E) It is a requirement of the Implementation Agreement in accordance with its Section 4.8, the Minister of Economy and Finance on behalf of Royal Government of Cambodia (the "Guarantor") has agreed to enter into this Guarantee of the payment obligations of EDC/MIME under the PTA and IA.

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

We hereby guarantee that:

1. The Guarantor hereby irrevocably and unconditionally guarantees and promises to pay to the Company any and every sum of money which is due and owed by MIME or EDC to Company under the IA or PTA that MIME or EDC has failed to pay in accordance with the terms of the IA or PTA (the "Guarantee").

2. This Guarantee shall be a continuing security and accordingly, shall extend to cover the balance due to the Company at any time from MIME or EDC under the IA or PTA, notwithstanding any notice of termination or the liquidation or other incapacity or any change in Royal Decree concerning MIME or EDC or in the name or style thereof or any settlement of account or other matter whatsoever.

3. Before taking steps to enforce this Guarantee and demand payment from the Guarantor, the Company shall be obliged only to make demand in writing for payment from MIME or EDC. After sixty (60) days from the date of the invoice(s) as specified in Section 11.1 of the PTA or any payment demand from the Company to MIME being received by EDC or MIME, the Company may notify the Guarantor in writing that payment from MIME or EDC is overdue and make a demand for payment from the Guarantor under this Guarantee, and the Guarantor shall make payment within thirty (30) Days. The Guarantor's late payment hereunder shall bear interest at an annual rate of LIBOR plus 3% (three percent). And no demand made by the Company hereunder shall prejudice or restrict the right of the Company to make further or other demands against any other unpaid invoice(s).

   All sums payable by the Guarantor under this Guarantee shall be fully paid to the bank account designated by the Company in the Kingdom of Cambodia in US Dollars to the Company.

4. Any demand for payment made pursuant to this Guarantee shall be made by courier or in person by a duly authorized officer of the Company at the Guarantor's offices and shall be accompanied by a certificate signed by a duly authorized officer of the Company stating, without the obligation to substantiate, that:

   "We hereby certify that:

   (1) Alex Corporation Co., Ltd. (the "Company") is making this demand on the Ministry of Economy and Finance (the "Guarantor") in the amount of U.S. Dollars ------------ [insert amount] in accordance with Section 1 of the Guarantee dated ---------------- between the Guarantor and the Company;

   (2) The amount specified above is due and payable by EDC/MIME under the PTA/IA between the Company and EDC/MIME and no part of the amount specified above is the subject of a dispute between the EDC/MIME and the Company;

   (3) Demand in writing for payment from MIME/EDC has been made;

   (4) Such amount, on the date hereof, remains unpaid by MIME/EDC."

5. The Guarantor represents and warrants that, as of the date hereof:

- The Guarantor has full power, authority, and legal right to incur the obligation, to execute and deliver, and to perform and observe the terms and provisions of this Guarantee.
- This Guarantee constitutes legal, valid, binding, and enforceable obligations of the Guarantor in accordance with its terms.
- All necessary action has been taken, and all approvals required have been obtained, under the Laws of the Kingdom of Cambodia to authorize the execution, delivery, and performance of this Guarantee.
- The obligations and covenants of the Guarantor in this Guarantee constitute unconditional obligations of the Guarantor, for the performance of which the full faith and credit of the Guarantor is pledged.
- The Guarantor unconditionally and irrevocably agrees that the execution, delivery, and performance by it of this Guarantee constitute commercial acts rather than public or governmental acts and such Guarantee constitutes our unconditional and irrevocable direct obligation.
- Should any proceedings be brought against it or its assets in any jurisdiction in relation to this Agreement, no immunity from such proceedings shall be claimed by or on its behalf or with respect to its assets which it now has or may acquire in the future.

6. This Guarantee shall remain in full force and effect from the Construction Commencement Date until the termination of the term of the IA or PTA and for so long thereafter as any amount owed to the Company by EDC in connection with such term is or may be outstanding. However, such Guarantee on PTA charges in the event of non-payment by EDC for the use of capacity of the Project shall be applicable from the Commercial Operation Date (COD) of the Project.

7. No failure or delay by the Company to exercise any right or remedy under this Guarantee shall constitute a waiver of that right or remedy. No single or partial exercise of any right or remedy shall preclude any other or further exercise thereof or the exercise of any other right or remedy. No waiver by the Company shall be effective unless it is in writing.

   The rights and remedies of the Company provided by this Guarantee are cumulative and not exclusive of any rights or remedies provided by law.

8. All notices or other communications (together "Notices") to be given or made hereunder shall be in writing, shall be addressed for the attention of the person indicated below and shall be delivered personally or by courier. All Notices shall be deemed delivered:

   (a) when presented personally, or

   (b) upon the day of duly recorded and receipted delivery by a recognized international document courier, addressed to the receiving Party, at the address indicated below (or such other address as such Party may have specified by notice delivered to the delivering Party at its address or facsimile number specified below).

The address for service of Notice shall be:

For the Guarantor:

Attention	: Minister, Ministry of Economy and Finance
Address	: Ministry of Economy and Finance Street No. 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, Kingdom of Cambodia
Facsimile	: +855 23 427 798

For the Company:

Address	: No. CE4, Street 265, Teuk Laak 3 commune, Toul Kok district, Phnom Penh, Kingdom of Cambodia.
Attention	: President
Facsimile	: +855 23 866 666

or such other addresses as either Party may have notified to the other Party.

9. The Guarantor shall not assign or transfer all or any part of its rights or obligations hereunder without the prior written consent of the Company, and the Company shall not assign or transfer all or any part of its rights or obligations hereunder without the prior written consent of the Guarantor. Notwithstanding the provision of the immediately preceding sentence, for the purpose of development or permanent financing of the Project, the Company may assign or create a security interest over its rights and interests in and to this Guarantee in favor of the Lenders. This Guarantee shall be binding upon and inure to the benefit of the Guarantor and the Company and the respective successors and permitted assignees of each Party.

10. The rights and obligations of the Guarantor and the Company under or pursuant to this Guarantee shall be governed by and construed according to the Laws of England, which shall also be the procedural law governing any arbitration.

11. If there is any dispute or difference of any kind whatsoever arising out of or in connection with this Guarantee, the Guarantor and the Company shall attempt for a period of thirty (30) days after the receipt by one Party of a notice from the other Party of the existence of the dispute to settle such dispute through mutual amicable discussions. Should such dispute cannot be resolved through mutual amicable discussions, then it shall be submitted to the Singapore International Arbitration Center for arbitration in accordance with the arbitration rules of the Singapore International Arbitration Center. And if there are discrepancies between this clause and the rules of the Singapore International Arbitration Center, this clause shall govern. The award rendered shall be in writing and shall be final, conclusive and binding upon the Guarantor and the Company and award thereon may be entered in any Cambodian court having jurisdiction for its enforcement. Such Parties shall execute and perform the award and each Party hereby irrevocably waives any right it may have to contest the validity of such award or the jurisdiction of the arbitration tribunal to hear any reference to arbitration to which this Guarantee applies. Any payment under arbitration award shall be payable in U.S. Dollars. The costs of arbitration shall be borne by the losing Party, unless otherwise determined by the arbitration tribunal. The Party that is responsible to pay an arbitration award shall pay interest at a rate of LIBOR plus 3% (three percent) to the other Party in receipt of such arbitration award from the due date for the payment of such award until the date of payment of such award.

12. The capitalized terms used but not defined in this Guarantee shall have the meanings given to them in the Power Transmission Agreement.

13. If one or more provisions contained in this Guarantee is held or found to be invalid, illegal, or unenforceable in any respect, the provision(s) shall be given effect to the extent permitted by law and the invalidity, illegality, or unenforceability of any provision shall not affect the validity of the remaining provisions of this Guarantee.
Subject to mutual agreement, no set-off, counterclaim, reduction, or diminution of any obligation that the Guarantor has or may have against the Company shall be available to the Guarantor against the Company in connection with any obligation of the Guarantor to the Company under this Guarantee.

14. This Guarantee shall expire upon the termination of the IA and PTA if no claim has been made and remains outstanding hereunder and any written demand made to us by you hereunder must therefore be received by us before that time.

15. This Guarantee shall become in full and effective on its ratification by legislatures of the Kingdom of Cambodia.

Yours faithfully,

Dr. AUN PORNMONIROTH
Minister, Ministry of Economy & Finance

CC :
- Ministry of the Royal Palace
- Secretariat of Senate
- Secretariat of National Assembly
- Council for the Development of Cambodia (CDC)
- Office of Council of Ministers
- Ministry of Foreign Affairs and International Cooperation
- Ministry of Industry, Mines, and Energy
- Cabinet of Samdech Akka Moha Sena Padei Techo HUN SEN, Prime Minister.
- Electricite du Cambodge (EDC)
- File

ព្រះរាជក្រម

នស/រកម/០១១៤/០០៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី៤ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ច្បាប់
ស្តីពី
ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាតិកា

ជំពូកទី ១ បទប្បញ្ញត្តិទូទៅ

មាត្រា ១.. គោលបំណង

មាត្រា ២.. គោលដៅ

មាត្រា ៣.. វិសាលភាព

មាត្រា ៤.. និយមន័យ

ជំពូកទី ២ សមត្ថកិច្ចគ្រប់គ្រង

មាត្រា ៥.. ភារកិច្ចរបស់ក្រសួងពាណិជ្ជកម្ម

មាត្រា ៦.. ក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

ជំពូកទី ៣ នីតិវិធីចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

ផ្នែកទី ១ អ្នកដាក់ពាក្យស្នើសុំនិងការដាក់ពាក្យស្នើសុំ

មាត្រា ៧.. អ្នកដាក់ពាក្យស្នើសុំ

មាត្រា ៨.. ការដាក់ពាក្យស្នើសុំចុះបញ្ជី

ផ្នែកទី ២ នីតិវិធីនៃការពិនិត្យពាក្យស្នើសុំ

មាត្រា ៩.. ការពិនិត្យពាក្យស្នើសុំចុះបញ្ជី

មាត្រា ១០.. ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដែលមិនអាចចុះបញ្ជីបាន

មាត្រា ១១.. ការត្រួតពិនិត្យខ្លឹមសារពាក្យស្នើសុំចុះបញ្ជី

មាត្រា ១២.. ការចុះបញ្ជីនិងការបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រផ្លូវការ

មាត្រា ១៣.. ការកែតម្រូវលើការកត់ត្រា

មាត្រា ១៤.. រូបសញ្ញាជាតិសម្រាប់បញ្ជាក់លើទំនិញសម្គាល់ភូមិសាស្ត្រ

ផ្នែកទី ៣ បណ្តឹងជំទាស់

មាត្រា ១៥.. រយៈពេលបណ្តឹងជំទាស់

មាត្រា ១៦.. លក្ខខណ្ឌបណ្តឹងជំទាស់

មាត្រា ១៧.. នីតិវិធីបណ្តឹងជំទាស់

ជំពូកទី ៤ បណ្តឹងតវ៉ា

មាត្រា ១៨.. សិទ្ធិនិងរយៈពេលនៃបណ្តឹងតវ៉ា

ជំពូកទី ៥ ការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេស

មាត្រា ១៩.. លក្ខខណ្ឌនៃការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេស

មាត្រា ២០.. នីតិវិធីចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេស

មាត្រា ២១.. បណ្តឹងជំទាស់និងបណ្តឹងតវ៉ាចំពោះម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេស

ជំពូកទី ៦ អានុភាពនៃការចុះបញ្ជី

មាត្រា ២២.. សិទ្ធិដែលទទួលបានពីការចុះបញ្ជី

មាត្រា ២៣.. កិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រកម្ពុជានិងបរទេស
មាត្រា ២៤.. រយៈពេលនៃកិច្ចការពារ
មាត្រា ២៥.. ការទទួលស្គាល់ការចុះបញ្ជី

ជំពូកទី ៧ ការត្រួតពិនិត្យអនុលោមភាពនៃសៀវភៅបន្ទុកក្នុងការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

មាត្រា ២៦.. ការត្រួតពិនិត្យអនុលោមភាព
មាត្រា ២៧.. ប្រសិទ្ធភាពរបស់អង្គភាពចេញវិញ្ញាបនបត្របញ្ជាក់ពីអនុលោមភាព

ជំពូកទី ៨ ការកែសម្រួលមោឃភាព និងការលុបម៉ាកសម្គាល់ភូមិសាស្ត្រទំនិញចេញពីបញ្ជី

មាត្រា ២៨.. ការកែសម្រួល
មាត្រា ២៩.. មូលដ្ឋាននៃការផ្តល់មោឃភាពនិងការលុបម៉ាកសម្គាល់ភូមិសាស្ត្រទំនិញចេញពីបញ្ជី
មាត្រា ៣០.. អានុភាពនៃមោឃភាពនិងការលុបការចុះបញ្ជី

ជំពូកទី ៩ ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនិងការទទួលស្គាល់ឬការបដិសេធម៉ាក

មាត្រា ៣១.. ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនិងម៉ាក

ជំពូកទី ១០ វិធានការបណ្តោះអាសន្ននិងវិធានការតាមមាត់ច្រកព្រំដែន

មាត្រា ៣២.. ការអនុវត្តវិធានការបណ្តោះអាសន្ននិងវិធានការតាមមាត់ច្រកព្រំដែន

ជំពូកទី ១១ ភ្នាក់ងារ

មាត្រា ៣៣.. ភ្នាក់ងារតំណាង
មាត្រា ៣៤.. លក្ខណសម្បត្តិ

ជំពូកទី ១២ បទបញ្ជានិងសេចក្តីណែនាំរដ្ឋបាល

មាត្រា ៣៥.. បទបញ្ជាអនុវត្ត

ជំពូកទី ១៣ ការអនុវត្តសន្ធិសញ្ញាអន្តរជាតិនិងការបកស្រាយ

មាត្រា ៣៦.. ការអនុវត្ត

ជំពូកទី ១៤ ការឃាត់ទុកនិងការរឹបអូស

មាត្រា ៣៧.. ការឃាត់ទុកនិងការរឹបអូស

ជំពូកទី ១៥ ទោសប្បញ្ញត្តិ

មាត្រា ៣៨.. បទក្លែងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ
មាត្រា ៣៩.. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

ជំពូកទី ១៦ អន្តរប្បញ្ញត្តិ

មាត្រា ៤០.. អន្តរប្បញ្ញត្តិ

ជំពូកទី ១៧ អវសានប្បញ្ញត្តិ

មាត្រា ៤១.. និរាករណ៍

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

មាត្រា ១.– គោលបំណង

ច្បាប់នេះមានគោលបំណងការពារកម្មសិទ្ធិបញ្ញារបស់ផលិតករ ប្រតិបត្តិករ និងការពារអ្នកប្រើប្រាស់ផលិតផលដែលពាក់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ព្រមទាំងរក្សាអត្តសញ្ញាណជាតិ និងពង្រឹងចំណេះដឹង ចំណេះធ្វើតាមបែបប្រពៃណី និងរួមចំណែកកាត់បន្ថយភាពក្រីក្រ ។

មាត្រា ២.– គោលដៅ

ច្បាប់នេះមានគោលដៅកំណត់ការគ្រប់គ្រង ការចុះបញ្ជី ការទទួលស្គាល់ និងការការពារម៉ាកសម្គាល់ ភូមិសាស្ត្រទំនិញនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣.– វិសាលភាព

ច្បាប់នេះមានវិសាលភាពអនុវត្តលើការចុះបញ្ជីនិងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្នុងព្រះរាជាណាចក្រកម្ពុជា ចំពោះទំនិញកសិផល ទំនិញកសិចំណីអាហារ ទំនិញសិប្បកម្ម ឬទំនិញផ្សេងៗទៀតដែលផលិតក្នុងតំបន់ភូមិសាស្ត្រឬកែច្នៃស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

មាត្រា ៤.– និយមន័យ

វាក្យសព្ទបច្ចេកទេសសំខាន់ៗដែលប្រើក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យដូចតទៅ៖

ការត្រួតពិនិត្យ សំដៅដល់ការត្រួតពិនិត្យផ្ទៃក្នុងនិងការត្រួតពិនិត្យពីខាងក្រៅ ។ ការត្រួតពិនិត្យសំដៅដល់ការផ្ទៀងផ្ទាត់អនុលោមភាពរបស់ផលិតផលជាមួយនឹងសៀវភៅបន្ទុក ដោយសមាគមសម្គាល់ភូមិសាស្ត្រទំនិញ និងអង្គភាពចេញវិញ្ញាបនបត្រឬអាជ្ញាធរដែលត្រូវបានចាត់តាំង ។

ការប្រើប្រាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ សំដៅដល់ការស្នើលក់ ការផលិត ការដាក់លក់ ការនាំចេញ និងការនាំចូលទំនិញសម្គាល់ភូមិសាស្ត្រ ។

ការនឹកគិតទៅដល់ សំដៅដល់ស្ថានភាពដែលការប្រើប្រាស់ពាក្យឬរូបភាពដើម្បីសម្គាល់ទំនិញមួយ ការបញ្ចូលផ្នែកនៃឈ្មោះឬរូបភាពនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដែលបានចុះបញ្ជីរួចធ្វើឱ្យអ្នកប្រើប្រាស់កើតមានអារម្មណ៍ថាជាទំនិញសម្គាល់ភូមិសាស្ត្រ ។

កិត្តិសព្ទ សំដៅដល់ការទទួលស្គាល់យ៉ាងទូលំទូលាយនូវទំនិញ និងឈ្មោះ ទំនិញនៅ ក្នុងផ្នែកផលិតកម្មឬពាណិជ្ជកម្មឬតាមរយៈការប្រើប្រាស់ទំនិញដែលពាក់ព័ន្ធ ។

ទំនិញដែលអាចប្រៀបធៀបបាន សំដៅដល់ទំនិញទាំងឡាយណាដែលមានទំនាក់ទំនងទៅនឹងចរិតលក្ខណៈគោលដៅឬការប្រើប្រាស់ដែលប្រហាក់ប្រហែលគ្នារបស់ទំនិញ ។

ទំនិញសម្គាល់ភូមិសាស្ត្រ សំដៅដល់ទំនិញពាក់ម៉ាកសម្គាល់ភូមិសាស្ត្រដែលបានចុះបញ្ជីរួច ។

នាមទូទៅ សំដៅដល់នាមដែលមហាជនស្គាល់ជាទូទៅថាជាការបង្ហាញពីប្រភេទនៃទំនិញ ។

បណ្តឹងជំទាស់ សំដៅដល់បណ្តឹងជំទាស់ទៅនឹងការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញណាមួយពីសំណាក់បុគ្គលពាក់ព័ន្ធ ។

បណ្តឹងតវ៉ា សំដៅដល់ការប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចចុងក្រោយរបស់ក្រសួងពាណិជ្ជកម្ម ឬក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ។

ប្រតិបត្តិករ សំដៅដល់បុគ្គលដែលពាក់ព័ន្ធនៅក្នុងដំណើរការប្រមូលទិញកែច្នៃធ្វើពាណិជ្ជកម្ម ឬចែកចាយទំនិញសម្គាល់ភូមិសាស្ត្រ ។

ព្រឹត្តិបត្រផ្លូវការ សំដៅដល់ព្រឹត្តិបត្រផ្លូវការរបស់ក្រសួងពាណិជ្ជកម្ម ។

ម៉ាក សំដៅដល់សញ្ញាដែលមើលឃើញហើយអាចសម្គាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវានៃសហគ្រាសនីមួយៗ ។

ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ សំដៅដល់ឈ្មោះ សញ្ញាសម្គាល់ និង/ឬ រូបភាព ផ្សេងៗទៀតដែលមានលក្ខណៈញែកដាច់ដែលជាឈ្មោះ ឬតំណាងឲ្យប្រភពដើមនៃតំបន់ភូមិសាស្ត្រមួយហើយឈ្មោះសញ្ញាសម្គាល់ និង/ឬ រូបភាពនោះសម្រាប់កំណត់អត្តសញ្ញាណទំនិញមានប្រភពក្នុងភូមិសាស្ត្រនោះដែលបានផ្តល់ជាមូលដ្ឋានគ្រឹះដល់គុណភាព កិត្តិសព្ទ ឬចរិតលក្ខណៈផ្សេងទៀតនៃទំនិញដែលកើតចេញពីតំបន់ភូមិសាស្ត្រនោះ ។

សវនាការ សំដៅដល់ការប្រជុំដោះស្រាយវិវាទរបស់មន្ត្រីកាន់កាប់បញ្ជីមុននឹងសម្រេចករណីជំទាស់នានារបស់ដើមបណ្តឹង ។

សេចក្តីថ្លែងតប សំដៅដល់ការផ្តល់ទឡ្ហីករណ៍ និងភស្តុតាងរបស់ភាគីណាមួយតតាំងទៅនឹងសេចក្តីរាយការណ៍របស់ភាគីបដិបក្ខ ។

សៀវភៅបន្ទុក សំដៅដល់ឯកសារកំណត់យ៉ាងច្បាស់លាស់នូវចំណុចសំខាន់ៗ អំពីតំបន់ភូមិសាស្ត្រនៃការផលិតលក្ខខណ្ឌនៃការផលិត និងដំណើរការត្រួតពិនិត្យគុណភាព ទំនិញសម្គាល់ភូមិសាស្ត្រជាដើម ដែលចងក្រងឡើងដោយអ្នកដាក់ពាក្យស្នើសុំ ។

អង្គភាពចេញវិញ្ញាបនបត្រ សំដៅដល់ស្ថាប័នសាធារណៈ ឬអង្គភាពឯកជនដែលចេញវិញ្ញាបនបត្របញ្ជាក់ពីអនុលោមភាពស្របតាមសៀវភៅបន្ទុក ។

ជំពូកទី ២
សមត្ថកិច្ចគ្រប់គ្រង

មាត្រា ៥.- ភារកិច្ចរបស់ក្រសួងពាណិជ្ជកម្ម

ក្រសួងពាណិជ្ជកម្មជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រង កាន់កាប់ និងចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៦.- ក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

ត្រូវរៀបចំឲ្យមានក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដើម្បីសិក្សា និងជំរុញមុខ

ទំនិញដែលមានសក្តានុពលអាចចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងដោះស្រាយបណ្តឹងតវ៉ាពីការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវកំណត់ដោយអនុក្រឹត្យ ។

ជំពូកទី ៣
នីតិវិធីចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ
ផ្នែកទី ១ អ្នកដាក់ពាក្យស្នើសុំនិងការដាក់ពាក្យស្នើសុំ

មាត្រា ៧.- អ្នកដាក់ពាក្យស្នើសុំ

សមាគមសម្គាល់ភូមិសាស្ត្រ ឬក្រុមតំណាងផលិតករ ឬអង្គភាពតំណាងផលិតករ និង/ឬប្រតិបត្តិករ ដែលអាចទទួលផលប្រយោជន៍ពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនោះ មានសិទ្ធិដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ។

ការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញកម្ពុជា ត្រូវធ្វើតាមរយៈសមាគមសម្គាល់ភូមិសាស្ត្រទំនិញ ។ អ្នកដាក់ពាក្យស្នើសុំ គឺជាម្ចាស់សិទ្ធិលើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្រោយការចុះបញ្ជី ។

ក្រុមផលិតករ ប្រតិបត្តិករ ស្ថាប័ន និង/ឬបុគ្គលពាក់ព័ន្ធ ដែលមានបំណងចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញកម្ពុជា ត្រូវរៀបចំបង្កើតជាសមាគមសម្គាល់ភូមិសាស្ត្រទំនិញ ដោយផ្អែកលើតំបន់ភូមិ-សាស្ត្រ និងមុខទំនិញមួយ ហើយត្រូវមានលក្ខន្តិកៈដើម្បីគ្រប់គ្រង និងចាត់ចែងការងាររបស់ខ្លួនក្នុងគោលដៅមិនរកប្រាក់ចំណេញ ។ សមាជិកភាពរបស់សមាគមត្រូវមានលក្ខណៈបើកចំហ ។ សមាគមសម្គាល់ភូមិសាស្ត្រទំនិញត្រូវមានការទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ច ។ លក្ខន្តិកៈរបស់សមាគមត្រូវយកមកតម្កល់នៅក្រសួងពាណិជ្ជកម្ម ។ សមាគមត្រូវធានាឲ្យសមាជិករបស់ខ្លួនអនុវត្តតាមសៀវភៅបន្ទុកនិងកាតព្វកិច្ចផ្សេងៗទៀតដែលកំណត់ដោយច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

មាត្រា ៨.- ការដាក់ពាក្យស្នើសុំចុះបញ្ជី

ពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវដាក់នៅក្រសួងពាណិជ្ជកម្ម ដោយភ្ជាប់មកជាមួយនូវសៀវភៅបន្ទុកនិងសំណុំឯកសារពាក់ព័ន្ធ ។ ទម្រង់បែបបទនៃការដាក់ពាក្យស្នើសុំគំរូសៀវភៅបន្ទុក និងសំណុំឯកសារពាក់ព័ន្ធសម្រាប់ការចុះបញ្ជីត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

ផ្នែកទី ២
នីតិវិធីនៃការពិនិត្យពាក្យស្នើសុំ

មាត្រា ៩.- ការពិនិត្យពាក្យស្នើសុំចុះបញ្ជី

ក្រសួងពាណិជ្ជកម្មត្រូវពិនិត្យពាក្យស្នើសុំនិងត្រូវឆ្លើយតបក្នុងរយៈពេលយ៉ាងយូរ ៤៥ (សែសិបប្រាំ) ថ្ងៃគិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

បន្ទាប់ពីបានពិនិត្យឃើញថា ពាក្យស្នើសុំបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌដែលបានកំណត់ ក្រសួងពាណិជ្ជកម្មត្រូវចេញលិខិតទទួលស្គាល់ការដាក់ពាក្យស្នើសុំនោះជាផ្លូវការ ។

ក្នុងករណីពិនិត្យឃើញថាពាក្យស្នើសុំមិនបានបំពេញគ្រប់គ្រាន់តាមលក្ខខណ្ឌដែលបានកំណត់ ក្រសួងពាណិជ្ជកម្មត្រូវចេញលិខិតឲ្យអ្នកដាក់ពាក្យស្នើសុំដើម្បីធ្វើការបំពេញបន្ថែម ឬកែតម្រូវដោយបញ្ជាក់ពីចំណុចខ្វះខាត ។ អ្នកដាក់ពាក្យស្នើសុំអាចធ្វើការបំពេញបន្ថែមឬកែតម្រូវពាក្យស្នើសុំក្នុងរយៈពេល ០៦(ប្រាំមួយ)ខែគិតចាប់ពីថ្ងៃចេញលិខិត ។ ពាក្យស្នើសុំចុះបញ្ជីនោះត្រូវចាត់ទុកថាបានបោះបង់ចោលប្រសិនបើគ្មានការបំពេញបន្ថែមឬការកែតម្រូវ ឬមិនបានផ្តល់នូវការឆ្លើយតបឬការពន្យល់ជាវិជ្ជមានក្នុងរយៈពេលដែលបានកំណត់ខាងលើ ។ក្រសួងពាណិជ្ជកម្មអាចពន្យារពេលបន្ថែម០៦ (ប្រាំមួយ)ខែទៀតសម្រាប់ការកែតម្រូវពាក្យស្នើសុំ ប្រសិនបើមានសំណូមពរសមហេតុផលពីអ្នកដាក់ពាក្យស្នើសុំ ។

ក្រសួងពាណិជ្ជកម្មត្រូវពិនិត្យឯកសារបំពេញបន្ថែមឬឯកសារកែតម្រូវនេះ និងត្រូវឆ្លើយតបក្នុងរយៈពេលយ៉ាងយូរ ៤៥ (សែសិបប្រាំ)ថ្ងៃគិតចាប់ពីថ្ងៃទទួលឯកសារបំពេញបន្ថែម ឬឯកសារកែតម្រូវនេះ ។

មាត្រា ១០.- ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដែលមិនអាចចុះបញ្ជីបាន

ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញមិនអាចចុះបញ្ជីបាន ប្រសិនបើ៖

ក-ម៉ាកនោះផ្ទុយនឹងច្បាប់ បទប្បញ្ញត្តិ តម្លៃសីលធម៌សង្គមសាសនាប្រពៃណីល្អរបស់ជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ ។

ខ-ម៉ាកនោះធ្វើឲ្យសាធារណជនយល់ខុសឬភាន់ច្រឡំពីចរិតលក្ខណៈ ដូចជាប្រភេទ គុណភាព ទីកន្លែងនៃប្រភពដើមដំណើរការផលិតឬការប្រើប្រាស់ ។

គ-ម៉ាកនោះត្រូវបានគេប្រើប្រាស់ជាឈ្មោះពូជដំណាំឬពូជសត្វ ។

ឃ-ម៉ាកនោះជានាមទូទៅ ។

មាត្រា ១១.- ការត្រួតពិនិត្យខ្លឹមសារពាក្យស្នើសុំចុះបញ្ជី

ក្រសួងពាណិជ្ជកម្មត្រូវត្រួតពិនិត្យខ្លឹមសារនៃពាក្យស្នើសុំលើចំណុចសំខាន់ៗដូចខាងក្រោម៖

១- ភាពត្រឹមត្រូវនៃព័ត៌មានលម្អិតក្នុងពាក្យស្នើសុំដូចមានចែងក្នុងមាត្រា ៧ និងមាត្រា ៨ នៃច្បាប់នេះ ។

២- ចំណុចទាំងឡាយដូចមានចែងក្នុងមាត្រា ៤ ត្រង់ចំណុចនិយមន័យ លើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងមាត្រា ១០ នៃច្បាប់នេះ ។

៣- ភាពជាក់ស្តែងនៅមូលដ្ឋានផលិតកម្ម ចំពោះម៉ាកសម្គាល់ភូមិសាស្ត្រទំនិញកម្ពុជា ។

៤- ចំពោះម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដែលមានសូរសំឡេងដូចគ្នា ត្រូវអនុវត្តតាមលក្ខខណ្ឌដែលកំណត់ដោយក្រសួងពាណិជ្ជកម្ម ។

ក្នុងការត្រួតពិនិត្យខ្លឹមសារនៃពាក្យស្នើសុំ ក្រសួងពាណិជ្ជកម្មអាចអញ្ជើញអ្នកដាក់ពាក្យស្នើសុំ ឬភាគីដែលមានការពាក់ព័ន្ធមកពន្យល់ ឬផ្តល់ភស្តុតាងបន្ថែម ។ ក្នុងករណីចាំបាច់ក្រសួងពាណិជ្ជកម្ម

អាចស្នើសុំមតិពីអ្នកជំនាញក្នុងវិស័យពាក់ព័ន្ធដើម្បីធ្វើការពិនិត្យពិចារណានិងសម្រេច ។

មាត្រា ១២.- ការចុះបញ្ជីនិងការបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រផ្លូវការ

ក្រសួងពាណិជ្ជកម្មត្រូវចុះបញ្ជី និងចេញវិញ្ញាបនបត្រជូនដល់អ្នកដាក់ពាក្យស្នើសុំ ក្រោយពីបានពិនិត្យឃើញថាពាក្យស្នើសុំត្រូវបានបំពេញស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

បន្ទាប់ពីបានចុះបញ្ជី ក្រសួងពាណិជ្ជកម្មត្រូវបោះពុម្ពផ្សាយការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្នុងព្រឹត្តិបត្រផ្លូវការ ដើម្បីទុកលទ្ធភាពឲ្យភាគីមានផលប្រយោជន៍ធ្វើការប្តឹងជំទាស់ទៅនឹងការចុះបញ្ជី ។

មាត្រា ១៣.- ការកែតម្រូវលើការកត់ត្រា

ក្រសួងពាណិជ្ជកម្ម អាចកែតម្រូវកំហុសផ្សេងៗក្នុងកំណត់ត្រាដែលបានធ្វើឡើងដោយអនុលោមតាមច្បាប់នេះឬបទប្បញ្ញត្តិដែលពាក់ព័ន្ធ ។

មាត្រា ១៤.- រូបសញ្ញាជាតិសម្រាប់បញ្ជាក់លើទំនិញសម្គាល់ភូមិសាស្ត្រ

ក្រសួងពាណិជ្ជកម្ម ត្រូវរៀបចំបង្កើតរូបសញ្ញាជាតិមួយសម្រាប់បញ្ជាក់លើគ្រប់មុខទំនិញសម្គាល់ភូមិសាស្ត្រដែលបានចុះបញ្ជីរួចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ជំពូកទី ៣
បណ្តឹងជំទាស់

មាត្រា ១៥.- រយៈពេលបណ្តឹងជំទាស់

ភាគីដែលមានការពាក់ព័ន្ធអាចប្តឹងជំទាស់នឹងការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញទៅក្រសួងពាណិជ្ជកម្មក្នុងរយៈពេល ៩០ (កៅសិប)ថ្ងៃគិតចាប់ពីកាលបរិច្ឆេទនៃការបោះពុម្ពផ្សាយការចុះបញ្ជីដូចមានចែងក្នុងមាត្រា ១២ នៃច្បាប់នេះ ។

មាត្រា ១៦.- លក្ខខណ្ឌបណ្តឹងជំទាស់

បណ្តឹងជំទាស់ចំពោះការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវមានមូលដ្ឋានណាមួយ ដូចខាងក្រោម ៖

ក-មិនស្របតាមមាត្រា ៤ ត្រង់ចំណុចនិយមន័យលើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនៃច្បាប់នេះ ។

ខ-ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដែលបានចុះបញ្ជីនោះ ជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដែលមិនអាចចុះបញ្ជីបានដូចមានចែងក្នុងមាត្រា ១០ នៃច្បាប់នេះ និងបទប្បញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា ១៧.- នីតិវិធីបណ្តឹងជំទាស់

ក្រសួងពាណិជ្ជកម្មត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ អំពីបណ្តឹងជំទាស់ដល់អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ។ អ្នកដាក់ពាក្យស្នើសុំមានរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃគិតចាប់ពីកាលបរិច្ឆេទជូនដំណឹងដើម្បីធ្វើសេចក្តីថ្លែងតប ។ ក្រសួងពាណិជ្ជកម្មអាចពន្យារពេល ៤៥ (សែសិបប្រាំ) ថ្ងៃទៀត ប្រសិនបើមានសំណូមពរពីអ្នកស្នើសុំ ។

ក្រសួងពាណិជ្ជកម្មត្រូវជូនដំណឹងពីសេចក្តីសម្រេចរបស់ខ្លួន ដោយមានបញ្ជាក់ពីហេតុផលសមស្របទៅអ្នកដាក់ពាក្យស្នើសុំនិងអ្នកបណ្តឹងជំទាស់ ។

អ្នកដាក់ពាក្យស្នើសុំ និង/ឬអ្នកបណ្តឹងជំទាស់អាចប្តឹងតវ៉ានឹងសេចក្តីសម្រេចរបស់ក្រសួងពាណិជ្ជកម្មស្របតាមមាត្រា ១៨ នៃច្បាប់នេះ ។

ក្នុងករណីចាំបាច់ឬតាមការស្នើសុំពីភាគីណាមួយ ក្រសួងពាណិជ្ជកម្មត្រូវរៀបចំឲ្យមានសវនាការលើបណ្តឹងជំទាស់ ។

សេចក្តីសម្រេចលើបណ្តឹងជំទាស់ត្រូវបោះពុម្ពផ្សាយនៅក្នុងព្រឹត្តិបត្រផ្លូវការ ។

នីតិវិធីលម្អិតនៃបណ្តឹងជំទាស់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

ជំពូកទី ៤
បណ្តឹងតវ៉ា

មាត្រា ១៨.- សិទ្ធិនិងរយៈពេលនៃបណ្តឹងតវ៉ា

បុគ្គលដែលពាក់ព័ន្ធអាចប្តឹងតវ៉ានឹងសេចក្តីសម្រេចរបស់ក្រសួងពាណិជ្ជកម្មទៅក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញឬទៅតុលាការមានសមត្ថកិច្ច ។

បុគ្គលដែលពាក់ព័ន្ធអាចប្តឹងតវ៉ា នឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញទៅតុលាការមានសមត្ថកិច្ច ។

បណ្តឹងតវ៉ាត្រូវធ្វើឡើងក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃគិតចាប់ពីថ្ងៃដែលបានទទួលដំណឹងពីសេចក្តីសម្រេច ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញលើបណ្តឹងតវ៉ា ត្រូវបោះពុម្ពផ្សាយនៅក្នុងព្រឹត្តិបត្រផ្លូវការនិងផ្សព្វផ្សាយជាសាធារណៈ ។

ជំពូកទី ៥
ការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេស

មាត្រា ១៩.- លក្ខខណ្ឌនៃការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេស

ការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេសអាចធ្វើទៅបាន លុះត្រាតែម៉ាកសម្គាល់ភូមិ-សាស្ត្រទំនិញនោះបានចុះបញ្ជីស្របតាមបទប្បញ្ញត្តិនានាក្នុងប្រទេសដើមរួចហើយ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ក្រសួងពាណិជ្ជកម្មមិនអនុញ្ញាតឲ្យចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ចំពោះម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេសណាដែលមិនបានទទួលកិច្ចការពារ ឬត្រូវបានបញ្ឈប់កិច្ចការពារ ឬត្រូវបានឈប់ប្រើប្រាស់ក្នុងប្រទេសដើមរបស់ខ្លួន ។

ក្រសួងពាណិជ្ជកម្មអាចចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេសបាន លុះត្រាតែការដាក់ពាក្យស្នើសុំនោះធ្វើឡើងដោយតំណាងស្របច្បាប់ ឬតំណាងរដ្ឋបាល ឬអាជ្ញាធរបរទេសនៃប្រទេសនោះតាមរយៈភ្នាក់ងារតំណាងស្របច្បាប់ដូចចែងក្នុងជំពូកទី ១១ នៃច្បាប់នេះ ។

មាត្រា ២០.- នីតិវិធីចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេស

ពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេស ត្រូវដាក់នៅក្រសួងពាណិជ្ជកម្ម ។

នីតិវិធីនៃការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេស ត្រូវអនុវត្តតាមបទប្បញ្ញត្តិដែលមានចែងក្នុងមាត្រា ៧ មាត្រា ៨ មាត្រា ៩ មាត្រា ១០ មាត្រា ១១ មាត្រា ១២ និងមាត្រា ១៣ នៃច្បាប់នេះ ។

ក្រោយពេលដាក់ពាក្យក្រសួងពាណិជ្ជកម្មមានសិទ្ធិតម្រូវឲ្យអ្នកដាក់ពាក្យស្នើសុំ បញ្ជូនរាល់ព័ត៌មានផ្សេងទៀតទាក់ទងនឹងការចុះបញ្ជីនៅបរទេស ដែលអាចជាមូលដ្ឋានសម្រាប់ការចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២១.- បណ្ដឹងជំទាស់និងបណ្ដឹងតវ៉ាចំពោះម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេស

បទប្បញ្ញត្តិស្ដីពីរយៈពេល លក្ខខណ្ឌ នីតិវិធីបណ្ដឹងជំទាស់ និងនីតិវិធីបណ្ដឹងតវ៉ានៃច្បាប់នេះ ត្រូវយកមកអនុវត្តចំពោះម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេស ។

ជំពូកទី ៦
អានុភាពនៃការចុះបញ្ជី

មាត្រា ២២.- សិទ្ធិដែលទទួលបានពីការចុះបញ្ជី

នៅពេលដែលម៉ាកសម្គាល់ភូមិសាស្ត្រទំនិញមួយត្រូវបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មស្របតាមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ សមាជិកសមាគមសម្គាល់ភូមិសាស្ត្រទំនិញដែលជាផលិតករ និង/ឬប្រតិបត្តិករដែលអនុវត្តស្របតាមសៀវភៅបន្ទុក មានសិទ្ធិប្រើប្រាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនោះ ។ សិទ្ធិប្រើប្រាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញមិនអាចផ្ទេរបានឡើយ ។

ម្ចាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញមានសិទ្ធិប្ដឹងទៅតុលាការមានសមត្ថកិច្ច ចំពោះបុគ្គលណាម្នាក់ដែលបានប្រើប្រាស់ដោយរំលោភនូវម៉ាកសម្គាល់ភូមិសាស្ត្រទំនិញរបស់ខ្លួន ដោយគ្មានការយល់ព្រមពីម្ចាស់នោះ ហើយក៏មានសិទ្ធិប្ដឹងចំពោះសមាជិកណាម្នាក់នៃសមាគមសម្គាល់ភូមិសាស្ត្រទំនិញដែលបានប្រើប្រាស់ដោយរំលោភនូវម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL ព្រះបរមរាជវាំង

នេះ នៅលើទំនិញដែលចេញមកពីតំបន់ភូមិសាស្ត្រផ្សេងៗទៀតផងដែរ ។

សិទ្ធិដែលទទួលបានតាមរយៈការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ មិនរាប់បញ្ចូលនូវការដាក់លក់ទំនិញនៅលើទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា ដោយម្ចាស់សិទ្ធិដែលបានចុះបញ្ជី ឬដោយមានការយល់ព្រមពីម្ចាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនោះទេ ។

មាត្រា ២៣.- កិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញកម្ពុជានិងបរទេស

ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញកម្ពុជានិងបរទេស ដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានការពារទល់នឹង ៖

ក-ការប្រើប្រាស់មិនត្រឹមត្រូវក្នុងគោលបំណងពាណិជ្ជកម្មដោយផ្ទាល់ ឬដោយប្រយោលនូវម៉ាកសម្គាល់ភូមិសាស្ត្រដែលបានចុះបញ្ជីរួចហើយ ចំពោះទំនិញដែលដូចគ្នាឬទំនិញដែលអាចប្រៀបធៀបបានទៅនឹងទំនិញដែលបានចុះបញ្ជីដើម្បីឲ្យការប្រើប្រាស់នោះទទួលផលប្រយោជន៍ ឬអាចនឹងទទួលផលប្រយោជន៍ពីកេរ្តិ៍ឈ្មោះរបស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ។

ខ-ការប្រើប្រាស់ដោយគ្មានការអនុញ្ញាត ការធ្វើត្រាប់តាម ការធ្វើឲ្យនឹកគិតទៅដល់ ឬការបកប្រែម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ទោះបីប្រភពពិតប្រាកដនៃទំនិញត្រូវបានអមដោយពាក្យដូចជា "ស្ទីល" "យថាប្រភេទ" "ប្រភេទ" "វិធីសាស្ត្រ" "របៀប" "ត្រាប់តាម" ឬការបកប្រែនៃពាក្យទាំងនេះ ឬពាក្យប្រហាក់ប្រហែលធ្វើឲ្យសាធារណជនភាន់ច្រឡំក៏ដោយ ។

គ-ការក្លែងបន្លំ ឬការធ្វើឲ្យភាន់ច្រឡំអំពីប្រភពដើម ប្រភេទ ឬគុណភាពពិសេសនៃទំនិញដែលបង្ហាញលើសំបកវេចខ្ចប់គ្រប់ប្រភេទ ឬលើឯកសារផ្សាយពាណិជ្ជកម្ម ឬលើឯកសារផ្សេងទៀតដែលទាក់ទងនឹងទំនិញ ដែលអាចនាំឲ្យមានការយល់ខុសអំពីប្រភពដើមរបស់ផលិតផល ។

ឃ-ការអនុវត្តផ្សេងៗទៀតដែលអាចធ្វើឲ្យសាធារណជនទូទៅភាន់ច្រឡំអំពីប្រភព ដើមពិតប្រាកដនៃទំនិញ។

មាត្រា ២៤.- រយៈពេលនៃកិច្ចការពារ

ការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវមានសុពលភាពចាប់ពីកាលបរិច្ឆេទនៃការទទួលពាក្យស្នើសុំចុះបញ្ជីប្រសិនបើគ្មានការលុបឬមោឃភាព ស្របតាមច្បាប់នេះ។

មាត្រា ២៥.- ការទទួលស្គាល់ការចុះបញ្ជី

ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដែលបានចុះបញ្ជីត្រឹមត្រូវរួចហើយមុនច្បាប់នេះចូលជាធរមានត្រូវមានសុពលភាពបន្ត ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ជំពូកទី៧
ការត្រួតពិនិត្យអនុលោមភាពនៃសៀវភៅបន្ទុក
ក្នុងការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

មាត្រា ២៦.- ការត្រួតពិនិត្យអនុលោមភាព

អ្នកដាក់ពាក្យស្នើសុំអាចជ្រើសរើសអង្គភាពចេញវិញ្ញាបនបត្រឬអង្គភាពត្រួតពិនិត្យដែលមានការចុះបញ្ជីស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជានិងមានការទទួលស្គាល់ពីក្រសួងពាណិជ្ជកម្ម ។ អង្គភាពចេញវិញ្ញាបនបត្រ ឬអង្គភាពត្រួតពិនិត្យជាអាជ្ញាធរសាធារណៈមានសមត្ថកិច្ចឬអង្គភាពឯកជនដែលទទួលស្គាល់ជាផ្លូវការដោយអង្គការស្តង់ដាអន្តរជាតិ ឬស្ថាប័នណាមួយដែលមានប្រព័ន្ធត្រួតពិនិត្យអាចជឿជាក់បាន ។

ក្នុងការត្រួតពិនិត្យក្រោយការចុះបញ្ជីក្រសួងពាណិជ្ជកម្មអាចអញ្ជើញម្ចាស់សិទ្ធិ ឬបុគ្គលដែលមានការពាក់ព័ន្ធមកផ្តល់ការពន្យល់ឬផ្តល់ភស្តុតាងបន្ថែម ។ ក្នុងករណីចាំបាច់ក្រសួងពាណិជ្ជកម្មអាចស្នើសុំមតិពីអ្នកជំនាញក្នុងវិស័យពាក់ព័ន្ធដើម្បីធ្វើការពិនិត្យពិចារណានិងសម្រេច ។

អង្គភាពចេញវិញ្ញាបនបត្រឬអង្គភាពត្រួតពិនិត្យត្រូវផ្ទៀងផ្ទាត់អនុលោមភាពរបស់ទំនិញសម្គាល់ភូមិសាស្ត្រជាមួយនឹងសៀវភៅបន្ទុក ។ អង្គភាពចេញវិញ្ញាបនបត្រ ឬអង្គភាពត្រួតពិនិត្យត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំជូនក្រសួងពាណិជ្ជកម្មជារៀងរាល់ឆ្នាំដោយរាប់បញ្ចូលនូវបញ្ជីឈ្មោះផលិតករប្រតិបត្តិករផលិតផលបរិមាណដែលខ្លួនបានបញ្ជាក់ទទួលស្គាល់និងវិធានការដែលបានដាក់ ចេញប្រសិនបើមាន ។ ក្រសួងពាណិជ្ជកម្មជាអ្នកកំណត់កាលបរិច្ឆេទនៃការផ្តល់របាយការណ៍ ដោយផ្អែកតាមរដូវប្រមូលផល ឬចុងការិយបរិច្ឆេទ ។ ចំពោះឯកសារក្រៅពីភាសាខ្មែរត្រូវភ្ជាប់មកជាមួយនូវការបកប្រែជាភាសាខ្មែរដោយមានការបញ្ជាក់ពីភាពត្រឹមត្រូវ ។

ក្នុងករណីដែលផលិតករ ឬប្រតិបត្តិករណាមួយ ឬច្រើន មិនបានបំពេញតាមលក្ខខណ្ឌនៅក្នុងសៀវភៅបន្ទុក អង្គភាពចេញវិញ្ញាបនបត្រ ឬអង្គភាពត្រួតពិនិត្យត្រូវរាយការណ៍ជូនក្រសួងពាណិជ្ជកម្មដើម្បីដាក់ចេញនូវវិធានការសមស្របដូចខាងក្រោម៖

១-ធ្វើការកត់សម្គាល់កំហុសនិងណែនាំ ។

២-ព្រមាន ។

៣-បដិសេធមិនទទួលស្គាល់ឡូត៍ណាមួយនៃផលិតផល ។

៤-មិនទទួលស្គាល់សិទ្ធិនៃការប្រើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញជាបណ្តោះអាសន្ន ។

៥-ហាមឃាត់ជាស្ថាពរការប្រើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ។

សមាគមសម្គាល់ភូមិសាស្ត្រទំនិញត្រូវអនុវត្តតាមការសម្រេចរបស់ក្រសួងពាណិជ្ជកម្ម ។

សមាគមសម្គាល់ភូមិសាស្ត្រទំនិញត្រូវរាយការណ៍ជូនក្រសួងពាណិជ្ជកម្ម ចំពោះការអនុវត្តតាមវិធានការរបស់ក្រសួង ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

មាត្រា ២៧.- ប្រសិទ្ធភាពរបស់អង្គភាពចេញវិញ្ញាបនបត្រពាក់ព័ន្ធនឹងលោមភាព

ក្រសួងពាណិជ្ជកម្ម ត្រូវពិនិត្យមើលពីប្រសិទ្ធភាពរបស់អង្គភាពដែលចេញវិញ្ញាបនបត្រ ឬអង្គភាពត្រួតពិនិត្យ ។ ក្នុងករណីគ្មានប្រសិទ្ធភាព ក្រសួងពាណិជ្ជកម្ម មានអំណាចបដិសេធជាលាយលក្ខណ៍អក្សរដោយមានសំអាងហេតុចំពោះអង្គភាពដែលចេញវិញ្ញាបនបត្រ ឬអង្គភាពត្រួតពិនិត្យនិងអាចឲ្យអ្នកដាក់ពាក្យស្នើសុំជ្រើសរើសអង្គភាពចេញវិញ្ញាបនបត្រឬអង្គភាពត្រួតពិនិត្យថ្មី ។

ក្នុងករណីចាំបាច់ ក្រសួងពាណិជ្ជកម្មអាចកំណត់បទប្បញ្ញត្តិបន្ថែមសម្រាប់ការត្រួតពិនិត្យក្រោយការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ។

ជំពូកទី៨
ការកែសម្រួល មោឃភាព និងការលុបម៉ាក
សម្គាល់ភូមិសាស្ត្រទំនិញចេញពីបញ្ជី

មាត្រា ២៨.- ការកែសម្រួល

ក្រោយការចុះបញ្ជី ម្ចាស់សិទ្ធិអាចស្នើសុំធ្វើការកែសម្រួលសៀវភៅបន្ទុកបាន ជាពិសេសលើចំណុចដែលទាក់ទងនឹងការវិវត្តចំណេះដឹងបច្ចេកទេស និងវិទ្យាសាស្ត្រនិងការកំណត់ព្រំដែនភូមិសាស្ត្រជាដើម ។

បុគ្គលដែលមានការពាក់ព័ន្ធអាចស្នើទៅក្រសួងពាណិជ្ជកម្ម ដើម្បីធ្វើការកែសម្រួលការចុះបញ្ជី និង/ឬសៀវភៅបន្ទុកបាន ។

ការកែសម្រួលសៀវភៅបន្ទុកអាចធ្វើទៅបាន លុះត្រាតែមិនប៉ះពាល់ដល់ចំណុចជាសារវន្តនៃការសម្រេចក្នុងការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ។

មាត្រា ២៩.- មូលដ្ឋាននៃការធ្វើមោឃភាព និងការលុបម៉ាកសម្គាល់ភូមិសាស្ត្រទំនិញចេញពីបញ្ជី

បុគ្គលដែលមានការពាក់ព័ន្ធអាចបញ្ជូនសេចក្តីសង្កេតទៅក្រសួងពាណិជ្ជកម្ម ដើម្បីធ្វើការណែនាំដល់សមាគម ។

បុគ្គលដែលមានការពាក់ព័ន្ធអាចស្នើសុំទៅក្រសួងពាណិជ្ជកម្មឲ្យផ្តល់មោឃភាព ឬលុបចោលការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបាន ។

ក្រសួងពាណិជ្ជកម្មអាចចាត់ទុកការចុះបញ្ជីជាមោឃៈប្រសិនបើ៖

១- មានលក្ខខណ្ឌណាមួយនៃមាត្រា ៤ ត្រង់ចំណុចនិយមន័យលើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ មាត្រា ៧ និង មាត្រា ១០ នៃច្បាប់នេះមិនត្រូវបានបំពេញ ។

២- ជឿជាក់ដោយផ្អែកលើភស្តុតាងដែលបង្ហាញថា ម្ចាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដែលបានចុះបញ្ជីរួចហើយ មិនមែនជាម្ចាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញស្របច្បាប់ ។

ក្រសួងពាណិជ្ជកម្មមានសិទ្ធិលុបម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដែលបានចុះបញ្ជីរួច ក្នុងករណី

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL
ផ្ទៃលិខិត

១-ម្ចាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដែលបានចុះបញ្ជីរួចហើយ ស្នើសុំលុប ។

២-ទំនិញសម្គាល់ភូមិសាស្ត្រដែលបានចុះបញ្ជីរួចហើយ បានបាត់បង់លក្ខណសម្បត្តិពិសេសជាទំនិញសម្គាល់ភូមិសាស្ត្រ ។

៣-ម្ចាស់សិទ្ធិមិនគោរព និងមិនអនុវត្តតាមលក្ខខណ្ឌនានាដូចមានចែងក្នុងពាក្យស្នើសុំ ។

៤-ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេសដែលមិនបានការពារ ឬបញ្ឈប់កិច្ចការពារឬមិនបានប្រើប្រាស់បន្តបន្ទាប់នៅក្នុងប្រទេសដើម ។

៥-អាសយដ្ឋានទំនាក់ទំនងក្នុងព្រះរាជាណាចក្រកម្ពុជារបស់ម្ចាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញមិនអាចទាក់ទងបានយ៉ាងតិចចំនួនបីដងតាមគ្រប់មធ្យោបាយក្នុងរយៈពេលបីខែ ។

៦-ម្ចាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដែលបានចុះបញ្ជីរួចហើយ មិនគោរពតាមលក្ខខណ្ឌនៃការតម្រូវឲ្យផ្ដល់ឯកសារគាំទ្រ ដូចមានចែងក្នុងមាត្រា ១៧ នៃច្បាប់នេះ ។

៧-ម្ចាស់សិទ្ធិអនុវត្តផ្ទុយនឹងច្បាប់ និងបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធនឹងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ។

មាត្រា ៣០.- អានុភាពនៃមោឃភាពនិងការលុបការចុះបញ្ជី

ក្រសួងពាណិជ្ជកម្មត្រូវពិនិត្យលើសេចក្ដីសង្កេតសំណើសុំមោឃភាព ឬសំណើសុំលុបដោយពិនិត្យភស្តុតាងជាក់ស្ដែងនិងវាយតម្លៃដើម្បីឈានដល់ការសម្រេចតម្កល់ កែតម្រូវឬលុបម៉ាកសម្គាល់ភូមិសាស្ត្រទំនិញចេញពីបញ្ជីស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

នីតិវិធីនៃការសម្រេចតម្កល់កែតម្រូវ ឬលុបម៉ាកសម្គាល់ភូមិសាស្ត្រទំនិញចេញពីបញ្ជីត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

មោឃភាពនៃការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវមានអានុភាពចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជី ។

ការលុបម៉ាកសម្គាល់ភូមិសាស្ត្រទំនិញត្រូវមានអានុភាពចាប់ពីកាលបរិច្ឆេទនៃការចេញសេចក្ដីសម្រេច ។

រាល់ការធ្វើមោឃភាពនិងការលុបម៉ាកសម្គាល់ភូមិសាស្ត្រទំនិញត្រូវកត់ត្រា និងបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រផ្លូវការនិងផ្សព្វផ្សាយជាសាធារណៈភ្លាម ។

ជំពូកទី៩
ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងការទទួលស្គាល់ឬការបដិសេធម៉ាក

មាត្រា ៣១.- ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនិងម៉ាក

ក្រសួងពាណិជ្ជកម្មត្រូវបដិសេធការស្នើសុំចុះបញ្ជីម៉ាកណាដែលដូច ឬប្រហាក់ប្រហែលធ្វើឲ្យភាន់ច្រឡំនឹងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដែលបានដាក់ពាក្យមុនកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកនេះ ចំពោះទំនិញដូចគ្នាដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់នេះ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

នៅពេលដែលម៉ាកសម្គាល់ភូមិសាស្ត្រទំនិញត្រូវបានចុះបញ្ជីស្របតាមច្បាប់នេះរួចជាស្ថាពរការស្នើសុំចុះបញ្ជីម៉ាកដែលស្របគ្នានឹងស្ថានភាពណាមួយក្នុងមាត្រា ២៣ នៃច្បាប់នេះហើយដែលទាក់ទងនឹងប្រភេទទំនិញដូចគ្នា ត្រូវបានបដិសេធ ។

ក្រសួងពាណិជ្ជកម្មត្រូវបដិសេធការស្នើសុំចុះបញ្ជីម៉ាកសាជាថ្មី ប្រសិនបើការស្នើសុំនោះរំលោភលើបទប្បញ្ញត្តិទាំងឡាយដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់នេះ ។ សេចក្តីសម្រេចបដិសេធនេះត្រូវធ្វើដោយក្រសួងពាណិជ្ជកម្មដោយខ្លួនឯងឬដោយមានសំណើពីបុគ្គលដែលពាក់ព័ន្ធ ។

ការប្រើប្រាស់ម៉ាកដែលពាក់ព័ន្ធនឹងចំណុចណាមួយនៃមាត្រា ២៣ នៃច្បាប់នេះ ដែលបានចុះបញ្ជីម៉ាកដោយសុចរិតរួចហើយ មុនកាលបរិច្ឆេទនៃកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ឬមុនកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនៅក្នុងព្រះរាជាណាចក្រកម្ពុជា អាចអនុញ្ញាតឲ្យបន្តប្រើប្រាស់ម៉ាកនោះបាន ប្រសិនបើគ្មានមូលដ្ឋានចាត់ទុកជាមោឃៈ ។

ជំពូកទី១០
វិធានការបណ្តោះអាសន្ននិងវិធានការតាមមាត់ច្រកព្រំដែន

មាត្រា ៣២.- ការអនុវត្តវិធានការបណ្តោះអាសន្ននិងវិធានការតាមមាត់ច្រកព្រំដែន

បទប្បញ្ញត្តិទាំងឡាយស្តីពីវិធានការបណ្តោះអាសន្ន និងវិធានការតាមមាត់ច្រកព្រំដែនដែលមានចែងក្នុងច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ព្រមទាំងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងវិធានការបណ្តោះអាសន្ននិងវិធានការតាមមាត់ច្រកព្រំដែនត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ។

ជំពូកទី១១
ភ្នាក់ងារ

មាត្រា ៣៣.- ភ្នាក់ងារតំណាង

ក្នុងករណីដែលលំនៅឋានអចិន្ត្រៃយ៍ឬទីតាំងប្រកបអាជីវកម្មសំខាន់របស់អ្នកដាក់ពាក្យស្នើសុំស្ថិតនៅក្រៅព្រះរាជាណាចក្រកម្ពុជាអ្នកដាក់ពាក្យស្នើសុំនោះ ត្រូវមានតំណាងជាភ្នាក់ងារដែលមានលំនៅឋាននិងកំពុងប្រកបវិជ្ជាជីវៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣៤.- លក្ខណសម្បត្តិ

អ្នកតំណាងដែលជាភ្នាក់ងារក្នុងការដាក់ពាក្យសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដូចមានចែងក្នុងប្រកាសស្តីពីភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជារបស់ក្រសួងពាណិជ្ជកម្ម ។

ជំពូកទី១២
បទបញ្ជានិងសេចក្តីណែនាំរដ្ឋបាល

មាត្រា ៣៥.- បទបញ្ជាអនុវត្តន៍

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មត្រូវចេញបទបញ្ជាចាំបាច់ណែនាំលម្អិតអំពីការអនុវត្តច្បាប់នេះ។

អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញត្រូវបង់កម្រៃរដ្ឋបាលក្នុងការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនិងកម្រៃពាក់ព័ន្ធនានា ដែលត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

ជំពូកទី១៣
ការអនុវត្តសន្ធិសញ្ញាអន្តរជាតិនិងការបកស្រាយ

មាត្រា ៣៦.- ការអនុវត្ត

បទប្បញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញាអន្តរជាតិអំពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដែលព្រះរាជាណាចក្រកម្ពុជាជាភាគីមួយនៃសន្ធិសញ្ញានោះត្រូវយកមកអនុវត្តជាមួយនឹងច្បាប់នេះបានផងដែរ ។

ក្នុងករណីមានទំនាស់ជាមួយនឹងមាត្រាទាំងឡាយនៃច្បាប់នេះបទប្បញ្ញត្តិនៃសន្ធិសញ្ញាអន្តរជាតិទាំងនោះត្រូវចាត់ទុកជាបទប្បញ្ញត្តិគោល ។

ជំពូកទី១៤
ការឃាត់ទុកនិងការរឹបអូស

មាត្រា ៣៧.- ការឃាត់ទុកនិងការរឹបអូស

តុលាការមានសមត្ថកិច្ចមានអំណាចបញ្ជាឲ្យឃាត់ទុកទំនិញ ប្រសិនបើមានការសង្ស័យថាទំនិញនោះមានការបំពានសិទ្ធិរបស់ម្ចាស់សិទ្ធិ ។

បញ្ញត្តិនៃកថាខណ្ឌទី១ខាងលើនេះ ត្រូវយកមកអនុវត្តផងដែរ ប្រសិនបើមានការសង្ស័យថាសម្ភារនិងឧបករណ៍សំខាន់ៗដែលប្រើប្រាស់ក្នុងការផលិតទំនិញនោះបំពានសិទ្ធិរបស់ម្ចាស់សិទ្ធិ ។

ទំនិញដែលមានការបំពានសិទ្ធិរបស់ម្ចាស់សិទ្ធិដែលត្រូវបាននាំចូល នាំចេញ លក់ ឬផ្តល់សម្រាប់លក់ត្រូវរឹបអូសដោយអាជ្ញាធរមានសមត្ថកិច្ចតាមសេចក្តីសម្រេចរបស់តុលាការ ទោះជាមាន ឬគ្មានអ្នកណាម្នាក់បានជាប់ទោសចំពោះបទល្មើសនោះក៏ដោយ ។

ជំពូកទី១៥
ទោសប្បញ្ញត្តិ

មាត្រា ៣៨.- បទក្លែងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៥(ប្រាំ)ឆ្នាំនិងពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន)រៀល ទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល ចំពោះ៖

-អំពើប្រើប្រាស់មិនត្រឹមត្រូវក្នុងគោលបំណងពាណិជ្ជកម្មដោយផ្ទាល់ឬដោយប្រយោលនូវម៉ាកសម្គាល់ភូមិសាស្ត្រដែលបានចុះបញ្ជីរួចហើយ ចំពោះទំនិញដែលដូចគ្នា ឬទំនិញដែលអាចប្រៀបធៀបបានទៅនឹងទំនិញដែលបានចុះបញ្ជីរួច ដើម្បីឲ្យការប្រើប្រាស់នោះទទួលផលប្រយោជន៍ ឬអាចនឹងទទួលផលប្រយោជន៍ពីកេរ្តិ៍ឈ្មោះរបស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

-អំពើប្រើប្រាស់ដោយគ្មានការអនុញ្ញាត ការធ្វើត្រាប់តាម ការធ្វើឲ្យនឹកគិតទៅដល់ ឬការបកប្រែម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ទោះបីជាប្រភពពិតប្រាកដនៃទំនិញត្រូវបានអមដោយពាក្យដូចជា "ស្ទីល" "យថាប្រភេទ" "ប្រភេទ" "វិធីសាស្ត្រ" "របៀប" "ត្រាប់តាម" ឬការបកប្រែនៃពាក្យទាំងនេះឬពាក្យប្រហាក់ប្រហែលធ្វើឲ្យសាធារណជនភាន់ច្រឡំក៏ដោយ

-អំពើក្លែងបន្លំឬធ្វើឲ្យភាន់ច្រឡំអំពីប្រភពដើម ប្រភេទ ឬគុណភាពពិសេសនៃទំនិញដែលបង្ហាញលើសំបកវេចខ្ចប់គ្រប់ប្រភេទ ឬលើឯកសារផ្សាយពាណិជ្ជកម្ម ឬលើឯកសារផ្សេងទៀតដែលទាក់ទងទៅនឹងទំនិញ ដែលអាចនាំឲ្យមានការយល់ខុសពីប្រភពដើមរបស់ផលិតផល

-អំពើផ្សេងៗទៀតដែលអាចធ្វើឲ្យសាធារណជនទូទៅភាន់ច្រឡំពីប្រភពដើមពិតប្រាកដនៃទំនិញ ។

មាត្រា ៣៩.– ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌ ដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា៣៨(បទក្លែងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ)ខាងលើនេះ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០ ០០០ ០០០(ម្ភៃលាន)រៀល ទៅ ៥០ ០០០ ០០០ (ហាសិបលាន)រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើនដូចតទៅនេះ៖

១-ការរំលាយតាមបែបបទកំណត់ដោយមាត្រា១៧០(ការរំលាយនីតិបុគ្គលនិងការជម្រះបញ្ជីនៃនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ។

២-ការដាក់ឲ្យស្ថិតក្រោមការតាមដានត្រួតពិនិត្យរបស់តុលាការតាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមព្រហ្មទណ្ឌ ។

៣-ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយឬច្រើនតាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមព្រហ្មទណ្ឌ ។

៤-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈតាមបែបបទកំណត់ដោយមាត្រា ១៧៣ (ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ) នៃក្រមព្រហ្មទណ្ឌ ។

៥-រឹបអូសវត្ថុឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើសតាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូសនិងសិទ្ធិតតិយជន) នៃក្រមព្រហ្មទណ្ឌ ។

៦-រឹបអូសផលទុនឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើសតាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូសនិងសិទ្ធិតតិយជន) នៃក្រមព្រហ្មទណ្ឌ ។

៧-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោសតាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមព្រហ្មទណ្ឌ ។

៥

៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមគ្រប់មធ្យោបាយតាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍) នៃក្រមព្រហ្មទណ្ឌ ។

ជំពូកទី១៦
អន្តរប្បញ្ញត្តិ

មាត្រា ៤០.- អន្តរប្បញ្ញត្តិ

បទដ្ឋានគតិយុត្តដែលនៅជាធរមាន ត្រូវបន្តអានុភាពអនុវត្តហូតដល់មានបទដ្ឋានគតិយុត្តថ្មីមកជំនួស ។

ជំពូកទី១៧
អវសានប្បញ្ញត្តិ

មាត្រា ៤១.- និរាករណ៍

បទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀតដែលមានអានុភាពនៅពេលច្បាប់នេះ ត្រូវបានអនុវត្ត ហើយផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវចាត់ទុកថា គ្មានអានុភាពត្រឹមទំហំដែលផ្ទុយនឹងច្បាប់នេះ ចាប់ពីថ្ងៃដែលច្បាប់នេះត្រូវបានអនុវត្ត។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៤

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧. ១៤០១. ០២១

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី
ហត្ថលេខា
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
ហត្ថលេខា
ស៊ុន ចាន់ថុល

លេខៈ ៩២ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៤
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១៣/១៤៣១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហៅភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ញាតូបនីយកម្មដល់លោក **ម៉ឺ ប៉ាវហុង** (MO BAOHONG) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៦៥ នៅខេត្តគ័ងតុង សាធារណរដ្ឋប្រជាមានិតចិន។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៣៨.១៣១២.១៤៥០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០១៣

លេខៈ ១៤០៣ ស.ណ
សំណៅដើម្បីមានតម្កល់ជាការចែកផ្សាយ
រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល
សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១៣/១៤៣៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ចូវ បូ** (ZHOU BO) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៩១ នៅខេត្តហ្សឺជាំង សាធារណរដ្ឋប្រជាមានិតចិន។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៩៥.១៣១២.១៤៥១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០១៣

លេខ:១៤០៤ ស.ណ
សំណៅចម្លងចេញពីច្បាប់ដើមត្រឹមត្រូវជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊យ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១៣/១៤៣៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លីម ជែហ៊ុន** (LIM JAE HUN) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី២១ ខែមករា ឆ្នាំ១៩៦៩ នៅខេត្តជៀលឡាប៊ុកដូ សាធារណរដ្ឋកូរ៉េ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពករ.១៣១២.១៤៥២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០១៣

លេខៈ១៤០៦ស.ណ

សំណៅចម្លងត្រឹមត្រូវតាមច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ [illegible] ឆ្នាំ២០១៣

អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១៣/១៤៣៤

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីសញ្ជាតិ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ជុង សេយ៉ុង** (JUNG SAEYOUNG) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៧០ នៅក្រុងជៀងសាំងបុកដូ សាធារណរដ្ឋកូរ៉េ។

មាត្រា ២ : សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រស.១៣១៤.១៤៥៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០១៣

លេខ:១៤០៥ស.ណ

សំណៅចម្លងចេញពីច្បាប់ដើមសម្រាប់ចែកផ្សាយ
រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១៣/១៤៣៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពី លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្លាស់លោកជំទាវ **យូ អយ** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំព្រះរាជាណាចក្រថៃ ចូលប្រទេសវិញ ដោយត្រូវចប់អាណត្តិបេសកកម្ម។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣ វល.១៣១២.១៤៥៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៣

លេខ ០៦ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មករា ឆ្នាំ២០១៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១៣/១៤៣៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងលោកជំទាវ **អ៊ិត សោភា** ជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំព្រះរាជាណាចក្រថៃ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពខល.១៣១២.១៤៥៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៣

លេខ ០១៧ ស.ណ
សំណៅដែលមានចុះហត្ថលេខាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១៣/១៤៣៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានត្ថមិជាតិសាសនា រត្តនត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ត្រាស់បង្គាប់

ផ្ទេរ និងតែងតាំង ឯកឧត្តម ស្រី ឈ្វីទី ពីនាយកព្រះរាជលេខាធិការដ្ឋាន ព្រះមហាក្សត្រ

ជា

នាយកព្រះរាជខុទ្ទកាល័យ ព្រះមហាក្សត្រ មានឋានៈស្មើ ទេសរដ្ឋមន្ត្រី

នរោត្តម សីហមុនី

៣រក.១៣១៧.១៤៥៦
បានប្រទានព្រះរាជលញ្ឆករហើយ
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៣

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ ១៤/១៣៣.....រ.ចច
រាជធានីភ្នំពេញ ថ្ងៃទី...៣១...ខែ ...ធ្នូ.......ឆ្នាំ..២០១៣
សម្តេចចៅហ្វាវាំងវរវៀងជ័យ អធិបតីស្រីឧត្តម គង់ សំអុល
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

ព្រះរាជក្រឹត្យ

នស/រកត/១២១៣/១៤៤០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឲ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៥ នៃរដ្ឋសភា នាថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ ថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា** នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តែងតាំងជាទីប្រឹក្សាផ្ទាល់ និងជំនួយការ លោកជំទាវ **ឃួន សុដារី** អនុប្រធានទី២ នៃរដ្ឋសភា ក្នុងនីតិកាលទី៥ ៖

ក. ទីប្រឹក្សាផ្ទាល់

១- ឯកឧត្តម	**ឡាច វ៉ាន់**	មានឋានៈស្មើ **រដ្ឋលេខាធិការ**
២- លោកជំទាវ	**ឃួន វីឡាវណ្ណ**	មានឋានៈស្មើ **រដ្ឋលេខាធិការ**
៣- លោកជំទាវ	**អ៊ុក ដារ៉ា**	មានឋានៈស្មើ **រដ្ឋលេខាធិការ**
៤- លោកជំទាវ	**សុខណា កុឡាបបុប្ផា**	មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**
៥- ឯកឧត្តម	**យូ ស៊ីថាន**	មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**
៦- ឯកឧត្តម	**ហុង ឌុល**	មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ខ. ជំនួយការ

លោកជំទាវ **រុន សុវណ្ណាទេវី** មានឋានៈស្មើ អគ្គនាយក

មាត្រា២ : សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ចរស. ១៣១២.១៤៥៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៣

លេខ: ០៧ ស.ណ

សំណៅដែលមានតម្លៃជាការចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១៣/១៤៤១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឲ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៥ នៃរដ្ឋសភា នាថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ ថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០៣/០០៧ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការ នៃក្រុមនីតិប្បញ្ញត្តិ
- បានទ្រង់យល់សេចក្តីសម្រេចលេខ១៥៣ រ.ស ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១២ របស់រដ្ឋសភា ស្តីពីការកែសម្រួលរចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅ នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា** នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តែងតាំងឯកឧត្តម **កែ គេតនិន ជាអគ្គនាយកសេវា និងបច្ចេកទេស** នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា។

មាត្រា២ : សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១៣

លេខ: ១៦ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ២០១៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១៣/១៤៤២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៥ នៃរដ្ឋសភានាថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និងថ្នាក់ដឹកនាំនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០៣/០០៧ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការ នៃក្រុមនីតិប្បញ្ញត្តិ
- បានទ្រង់យល់សេចក្តីសម្រេចរួមលេខ ០០៥ ព.រ.ក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈសម្រាប់មន្ត្រីរាជការ នៃក្រុមនីតិប្បញ្ញត្តិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ។

ត្រាស់បង្គាប់

មាត្រា១: ដាក់ឱ្យចូលនិវត្តន៍ឯកឧត្តម **នៀម ជូឡេង** នៅក្នុងឋានន្តរសក្តិឧត្តមអភិបាលថ្នាក់ទី១ នៃក្របខ័ណ្ឌមន្ត្រីរាជការ នៃក្រុមនីតិប្បញ្ញត្តិ នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៤តទៅ។

មាត្រា២: សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរស.១៣១២.១៤៤០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១៣

លេខ: ១៥ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមករា ឆ្នាំ២០១៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១៣/១៤៤៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **គឹម សុខុន** ជាអនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចរល.១៣១២.១៤៦២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៣

លេខៈ ១១ ស.ណ
សំណៅដែលមានអត្ថបទតាមការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១៣/១៤៤៤

ស្តីពី

ការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា១.-

ត្រូវបានបង្កើត គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សរសេរជាអក្សរកាត់ថា

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL

គ.ស.ហ. មានភារកិច្ចដឹកនាំ រៀបចំ សម្របសម្រួលការអនុវត្ត តាមដាន និងត្រួតពិនិត្យការអនុវត្តគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល មានជាអាទិ៍ ការងារពាក់ព័ន្ធនឹងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងការអភិវឌ្ឍវិស័យឯកជន, ព្រមទាំងសម្របសម្រួលរាល់កិច្ចសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍឬការងារកែទម្រង់ ក្នុងវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ របស់រាជរដ្ឋាភិបាល ជាមួយដៃគូអភិវឌ្ឍន៍។

ជំពូកទី២
សមាសភាពនិងរចនាសម្ព័ន្ធ

មាត្រា២.-

គ.ស.ហ. មានសមាសភាពដូចតទៅ៖

១- ឧបនាយករដ្ឋមន្ត្រី មួយរូប	ប្រធាន
២- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	អនុប្រធានប្រចាំការ
៣- ទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា	អនុប្រធាន
៤- ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ឬតំណាង	អនុប្រធាន
៥- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
៦- រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម	សមាជិក
៧- រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម	សមាជិក
៨- រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល	សមាជិក
៩- រដ្ឋមន្ត្រីក្រសួងផែនការ	សមាជិក
១០- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	សមាជិក
១១- រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម	សមាជិក
១២- រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍	សមាជិក
១៣- រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន	សមាជិក
១៤- រដ្ឋមន្ត្រីក្រសួងទេសចរណ៍	សមាជិក
១៥- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី មួយរូប	សមាជិក
១៦- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	សមាជិក។

គ.ស.ហ. អាចមានសមាសភាពបន្ថែម ជារដ្ឋមន្ត្រី ប្រធានស្ថាប័ន ឬតំណាងនៃក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត នៃរាជរដ្ឋាភិបាល តាមការចាំបាច់។

សមាសភាពជាក់ស្តែងនៃ **គ.ស.ហ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

មាត្រា៣.-

ក្នុងការបំពេញភារកិច្ចដូចមានចែងក្នុងមាត្រា១ **គ.ស.ហ.** មានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យឯកជន ជាសសរស្តម្ភ សម្រាប់ជួយដឹកនាំ រៀបចំ សម្របសម្រួលការអនុវត្ត តាមដាន និងត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់ ឬកម្មវិធីនិង/ឬផែនការអភិវឌ្ឍសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ របស់រាជរដ្ឋាភិបាល ព្រមទាំងសម្រាប់ជួយសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ដែលមានការពាក់ព័ន្ធ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបង្កើតឡើងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីប្រធាន គ.ស.ហ.។

គណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ត្រូវបង្កើតឡើងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីប្រធាន គ.ស.ហ.។

គណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យឯកជន ត្រូវបង្កើតឡើងដោយអនុក្រឹត្យ តាមសំណើរបស់អនុប្រធានទី១ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បន្ទាប់ពីមានការឯកភាពពីប្រធាន គ.ស.ហ.។

គ.ស.ហ. អាចមានគណៈកម្មាធិការ អនុគណៈកម្មាធិការ ឬក្រុមការងារផ្សេងទៀត ដើម្បីបម្រើឱ្យការងារគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមតម្រូវការចាំបាច់។ គណៈកម្មាធិការ អនុគណៈកម្មាធិការ ឬក្រុមការងាររបស់ គ.ស.ហ. ត្រូវបង្កើតឡើងដោយអនុក្រឹត្យ ឬសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល តាមសំណើរបស់ប្រធាន គ.ស.ហ.។

ជំពូកទី៣
ដំណើរការការងារ

មាត្រា៤.-

តាមការអញ្ជើញរបស់ប្រធាន សមាជិក និងអនុប្រធាន គ.ស.ហ. ត្រូវចូលរួមប្រជុំ ឬចាត់តាំងតំណាងដែលមានសិទ្ធិសម្រេចជំនួស ដើម្បីចូលរួមប្រជុំ ក្នុងករណីអវត្តមាន ឬមានធុរៈ។

ក្នុងករណីប្រធានអវត្តមានឬមានធុរៈ អនុប្រធានប្រចាំការ បំពេញមុខងារជាប្រធានស្តីទី លើការងារអញ្ជើញនិងដឹកនាំការប្រជុំរបស់ គ.ស.ហ.។

គ.ស.ហ. ប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ដំណើរការការងារ។

មាត្រា៥.-

ប្រធាន គ.ស.ហ. មានសិទ្ធិអញ្ជើញប្រធានស្ថាប័ន ឬតំណាងរបស់ប្រធានស្ថាប័ន ឬអាជ្ញាធរ ព្រមទាំងមន្ត្រីបច្ចេកទេសនៃក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ចូលរួមប្រជុំនិងបំពេញការងារ ស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងព្រះរាជក្រឹត្យនេះ។

មាត្រា៦.-

គ.ស.ហ. ព្រមទាំងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ ឬអភិវឌ្ឍតាមវិស័យ អនុគណៈកម្មាធិការ និងក្រុមការងារបច្ចេកទេស មានសិទ្ធិអញ្ជើញតំណាងដៃគូអភិវឌ្ឍន៍ តំណាងវិស័យឯកជន តំណាងសង្គមស៊ីវិល ទីប្រឹក្សា ឬអ្នកជំនាញការជាតិ និងអន្តរជាតិ ចូលរួមប្រជុំ ក្នុងឋានៈជាសមាជិក អ្នកសង្កេតការណ៍ ឬអ្នកផ្តល់យោបល់ តាមការចាំបាច់។

មាត្រា៧.-

គ.ស.ហ. មានអគ្គលេខាធិការដ្ឋានមួយ ជាសេនាធិការ សម្រាប់បំពេញមុខងាររបស់ខ្លួន។

អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញមុខងារបន្ថែមជាអគ្គលេខាធិការដ្ឋាន គ.ស.ហ.។

មាត្រា៨.-

ក្នុងការបំពេញមុខងាររបស់ខ្លួន អគ្គលេខាធិការដ្ឋាន គ.ស.ហ. មានភារកិច្ចសម្របសម្រួលការរៀបចំនិងការ

អនុវត្តការងារគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចតទៅ÷

- សម្របសម្រួលការងារប្រចាំថ្ងៃរបស់ **គ.ស.ហ.** ស្របតាមការណែនាំនិងការសម្រេចរបស់ **គ.ស.ហ.**
- សហការ និងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអង្គភាពនានារបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានា ក្នុងការអនុវត្ត ការតាមដាន និងត្រួតពិនិត្យការអនុវត្តគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល
- រៀបចំ និងចាត់ចែងកិច្ចប្រជុំទាំងអស់របស់ **គ.ស.ហ.** តាមការណែនាំរបស់ប្រធាន **គ.ស.ហ.**
- សម្របសម្រួល និងរៀបចំកិច្ចពិគ្រោះយោបល់នានា ទាំងកម្រិតជាតិ និងអន្តរជាតិអំពីគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល និង
- បំពេញការងារផ្សេងទៀតតាមការកំណត់របស់ **គ.ស.ហ.**។

ជំពូកទី៤

អវសានប្បញ្ញត្តិ

មាត្រា៩.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា១០.-

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣

នស.១២១៣.១៤៦៣

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

លេខ: ២៩ ស.ណ

សំណៅដែលមានតម្លៃជាការចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែមករា ឆ្នាំ២០១៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១៣/១៤៤៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦០៦/០២០ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

ត្រាស់បង្គាប់

មាត្រា ១.-

ត្រូវបានបង្កើត**ខេត្តត្បូងឃ្មុំ** ដោយកាត់យកក្រុងចំនួន **០១** និងស្រុកចំនួន **០៦** ពីខេត្តកំពង់ចាមគឺ ក្រុងសួង ស្រុកត្បូងឃ្មុំ ស្រុកអូររាំងឪ ស្រុកក្រូចឆ្មារ ស្រុកតំបែរ ស្រុកពញាក្រែក និងស្រុកមេមត់។

ព្រំប្រទល់រដ្ឋបាល**ខេត្តត្បូងឃ្មុំ** ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យនេះ។

មាត្រា ២.-

ទីតាំងសាលា**ខេត្តត្បូងឃ្មុំ** ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

មាត្រា ៣.-

ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាល**ខេត្តត្បូងឃ្មុំ** ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៥.-

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស/រកត/១២១៣/១៤៦៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៣

លេខៈ ១៣ ស.ណ
សំណៅដែលមានតម្លៃសម្រាប់ការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ២០១៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០១១៤/០០១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០២/ ០១៥ ចុះថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩៤២ ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១១៣/១២៦៨ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងតែងតាំងបន្ថែមសមាសភាពថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **ថៃ ហ្វា** ជាទីប្រឹក្សានៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានឋានៈស្មើ រដ្ឋលេខាធិការ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តតាមព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ ២០ ស.ណ
សំណៅដែលមាន[illegible]ជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ០[illegible] ខែ មករា ឆ្នាំ២០១៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
សុយ សុខា

៣ទល. ១៤០១.០០១

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០១៤

ព្រះរាជក្រឹត្យ

នស/រកត/០១១៤/០០២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយដើម្បីបង្កើត ឬទិញប្រកាសនីយបត្រអាជ្ញាប័ណ្ណ ម៉ាកសម្គាល់ សិទ្ធិប្រហាក់ប្រហែល និងកម្មវិធីកុំព្យូទ័រ ។

ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានទិញបង្កើតប្រកាសនីយបត្រ អាជ្ញាប័ណ្ណ ម៉ាកសម្គាល់សិទ្ធិប្រហាក់ប្រហែល និងកម្មវិធីកុំព្យូទ័រ
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ នៃប្រកាសនីយបត្រ អាជ្ញាប័ណ្ណ ម៉ាកសម្គាល់សិទ្ធិប្រហាក់ប្រហែល និងកម្មវិធីកុំព្យូទ័រ ដែលបានបន្ថយដោយលក់ធ្វើអំណោយផ្ទេរ ឬជម្រះ
សមតុល្យ : ឥណាយិកបង្ហាញតម្លៃប្រកាសនីយបត្រអាជ្ញាប័ណ្ណ ម៉ាកសម្គាល់ សិទ្ធិប្រហាក់ប្រហែល និងកម្មវិធីកុំព្យូទ័រ ដែលកំពុងមាន ។
ចំណាំ : គណនីនេះត្រូវចែកទៅជាអនុគណនីសម្រាប់ប្រកាសនីយបត្រ អាជ្ញាបណ្ណ សិទ្ធិប្រហាក់ប្រហែល កម្មវិធីកុំព្យូទ័រ និងសោហ៊ុយផ្សេងៗទៀត ។

០៧ - គណនី ដីធ្លី ដីរ៉ែ និង សម្បត្តិធម្មជាតិផ្សេងៗ "លេខ ២១១"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រានូវតម្លៃដីធ្លី ដែលបានទិញពីអំណោយ និងបានពីរូបភាពផ្សេងទៀត ហើយបានបញ្ចូលជាទ្រព្យសម្បត្តិរបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ។

ការកត់ត្រា :
ឥណពន្ធ : កត់ត្រាតម្លៃដីធ្លី ដែលបានបញ្ចូលជាទ្រព្យសម្បត្តិរបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
ឥណទាន : កត់ត្រាតម្លៃដីធ្លី ដែលបានបន្ថយដោយ លក់ អំណោយ ផ្ទេរ ឬជម្រះ
សមតុល្យ : ឥណាយិក បង្ហាញតម្លៃដីធ្លីដែលកំពុងមាន ។
ចំណាំ : អនុគណនីដីធ្លី (លេខ ២១១១) ពុំមានការគិតរំលស់ទេ ។

០៨ - គណនី ការរៀបចំកែលម្អ ដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិផ្សេងៗ "លេខ ២១២"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយលើការរៀបចំកែលម្អដីធ្លី ។

ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយលើការកែលម្អដីធ្លី

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបានជម្រះជាមួយនឹងទឹកប្រាក់រំលស់បូកបន្ត និងគណនីតម្លៃគណនេយ្យនៃចំណែកសកម្មដែលបានលក់ ឬជម្រះ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់ដែលបានចំណាយលើការកែលម្អដីធ្លីដែលពុំទាន់បានជម្រះ ។

០៩ - គណនី សំណង់ និងការរៀបចំកែលម្អ អគារ "លេខ ២១៣"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយលើការទិញ ការសាងសង់ និងការកែលម្អអាគារ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយលើការទិញ ការសាងសង់ និងការកែលម្អអាគារ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបានជម្រះជាមួយនឹងទឹកប្រាក់រំលស់បូកបន្ត និងគណនីតម្លៃគណនេយ្យនៃចំណែកសកម្មដែលបានលក់ ឬជម្រះ ឬផ្ទេរ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់នៃតម្លៃអាគារដែលបានចំណាយលើការទិញ ការសាងសង់ និងចំនួនទឹកប្រាក់ចំណាយលើការកែលម្អអាគារ ។

<u>ចំណាំ</u> : គណនីនេះត្រូវចែកទៅជាអនុគណនីសម្រាប់សំណង់អាគារ ការរៀបចំកែលម្អអគារ និងសំណង់ផ្សេងៗ។

១០ - គណនី ឋបនកម្មបច្ចេកទេស សម្ភារៈ និងហត្ថូបករណ៍ "លេខ ២១៥"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រានូវតម្លៃឋបនកម្មបច្ចេកទេស សម្ភារៈ ហត្ថូបករណ៍ដែលបានពីការទិញ ពីអំណោយ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាតម្លៃឋបនកម្មបច្ចេកទេស សម្ភារៈ និងហត្ថូបករណ៍ដែលបានបញ្ចូលជាទ្រព្យសម្បត្តិរបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

ឥណទាន : កត់ត្រាតម្លៃឋបនកម្មបច្ចេកទេស សម្ភារៈ និងហត្ថូបករណ៍ដែលបានបន្ថយដោយលក់ ធ្វើអំណោយ ជម្រះ ឬផ្ទេរ

សមតុល្យ : ឥណពន្ធ បង្ហាញតម្លៃឋបនកម្មបច្ចេកទេស សម្ភារៈ ហត្ថូបករណ៍ ដែលកំពុងមាន ។

<u>ចំណាំ</u> : គណនីនេះត្រូវចែកទៅជាអនុគណនីសម្រាប់ឋបនកម្មបច្ចេកទេសសម្ភារៈ គ្រឿងឧបករណ៍ (ហត្ថូបករណ៍) និងគ្រឿងសម្ភារៈផ្សេងៗ ។

១១ - គណនី អចលកម្មរូបី ផ្សេងៗ "លេខ ២១៨"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រានូវតម្លៃអចលកម្មរូបីផ្សេងៗដែលបានពីទិញ អំណោយ និងពីការផលិត ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាតម្លៃអចលកម្មរូបី ដែលបានបញ្ចូលជាទ្រព្យសម្បត្តិរបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

ឥណទាន : កត់ត្រាតម្លៃអចលកម្មរូបីដែលបានបន្ថយដោយលក់ អំណោយ ផ្ទេរ ឬជម្រះ

សមតុល្យ : ឥណពន្ធ បង្ហាញតម្លៃអចលកម្មរូបីផ្សេងៗដែលកំពុងមាន ។

<u>ចំណាំ</u> : គណនីនេះត្រូវចែកទៅជាអនុគណនីសម្រាប់សម្ភារៈឧបករណ៍ដឹកជញ្ជូន សម្ភារៈឧបករណ៍ការិយាល័យ សម្ភារៈព័ត៌មានវិទ្យា និងទូរគមនាគមន៍ សង្ហារឹម និងអចលកម្មរូបីផ្សេងទៀត ។

១២ - គណនី អចលកម្មកំពុងដំណើរការ "លេខ ២៣១"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រានូវតម្លៃអចលកម្មរូបីដែលកំពុងដំណើរការសាងសង់ ផលិត ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាតម្លៃអចលកម្មរូបី ដែលកំពុងដំណើរការសាងសង់ ផលិត

ឥណទាន : កត់ត្រាតម្លៃអចលកម្មរូបី ដែលបានផ្ទេរទៅគណនី អចលកម្មរូបី ដែលពាក់ព័ន្ធ

សមតុល្យ : ឥណពន្ធ បង្ហាញតម្លៃអចលកម្មរូបី ដែលកំពុងដំណើរការសាងសង់-ផលិត ។

<u>ចំណាំ</u> : គណនីលេខ ២៣១ ត្រូវចែកទៅជាអនុគណនីសម្រាប់ការកែលម្អ ដីធ្លី អគារ ឋបនកម្មបច្ចេកទេស ។

១៣ - គណនី មូលបត្រនៃភាគកម្ម "លេខ ២៦១"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់បានចំណាយលើការវិនិយោគលើមូលបត្រជាមួយសហគ្រាស ក្រុមហ៊ុន ឬស្ថាប័នហិរញ្ញវត្ថុ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានវិនិយោគលើមូលបត្រ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់មូលបត្រដែលបានលក់ ឬជម្រះ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ដែលបានវិនិយោគលើមូលបត្រ ដែលពុំទាន់បានជម្រះឬលក់ចេញ ។

ចំណាំ :- គណនីនេះ ត្រូវតាមដានលម្អិតទៅតាមប្រភេទមូលបត្រដែលបានវិនិយោគ ។

- ចំនួនទឹកប្រាក់ដែលកត់ត្រាក្នុងគណនីនេះ គឺទាក់ទងតែនឹងប្រាក់ដើមតែប៉ុណ្ណោះ ។

១៤ - គណនី ការឱ្យខ្ចី "លេខ ២៧១"

ការកត់ត្រា : គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានផ្តល់ឱ្យអង្គភាព ស្ថាប័នផ្សេងៗខ្ចីប្រាក់ ។ ការកត់ត្រាក្នុងគណនីនេះតែចំនួនទឹកប្រាក់ដើមដែលបានឱ្យខ្ចី និងបានសងមកវិញ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដើមដែលបានឱ្យខ្ចី

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដើមដែលបានសងមកវិញ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ឱ្យខ្ចីដែលពុំទាន់បានសងមកវិញ ។

១៥ - គណនី វិលស់អចលកម្មអរូបី "លេខ ២៨០"

ការកត់ត្រា : គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មអរូបី ។ គណនីនេះកត់ត្រាបដិភាគ និងគណនីទាយជ្ជទានឱ្យដល់រំលស់អចលកម្មអរូបី ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មអរូបីដែលបានជម្រះជាមួយតម្លៃអចលកម្មអរូបី

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មអរូបីក្នុងឆ្នាំដែលបានចាត់ជាចំណាយចរិកាចរន្ត

សមតុល្យ : ឥណទាយីបង្ហាញចំនួនទឹកប្រាក់រំលស់អចលកម្មអរូបីបូកបន្ត ។

ចំណាំ :- គណនីលេខ ២៨០ ត្រូវចែកទៅជាអនុគណនីសម្រាប់រំលស់ទៅតាមប្រភេទអចលកម្ម ។

- ការជម្រះចំនួនទឹកប្រាក់ខាងឥណពន្ធនៃគណនីរំលស់អចលកម្មអរូបីយោងលើការលក់ចេញ ការបោះបង់ចោល ការបាត់បង់ និងការផ្ទេរ ។

- ករណីដែលចំនួនទឹកប្រាក់រំលស់បូកបន្តនៃអចលកម្មស្មើនឹងតម្លៃបញ្ចូល គឺត្រូវបញ្ឈប់ការធ្វើទាយជ្ជទានរំលស់ ។ ការជម្រះលុះត្រាតែអចលកម្មនោះឈប់ប្រើប្រាស់ ។

១៦ - គណនី រំលស់អចលកម្មរូបី "លេខ ២៨១"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មរូបី ។ គណនីនេះកត់ត្រាបដិភាគ និងគណនីទាយជ្ជទានឱ្យដល់រំលស់អចលកម្មរូបី ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មរូបីដែលបានជម្រះជាមួយតម្លៃអចលកម្មរូបី

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មរូបីក្នុងឆ្នាំដែលបានចាត់ជាចំណាយចរិកាចរន្ត

សមតុល្យ : ឥណទាយីបង្ហាញចំនួនទឹកប្រាក់រំលស់អចលកម្មរូបីបូកបន្ត ។

ចំណាំ :- គណនីលេខ ២៨០ ត្រូវចែកទៅជាអនុគណនីសម្រាប់រំលស់ទៅតាមប្រភេទអចលកម្ម ។

- ការជម្រះចំនួនទឹកប្រាក់ខាងឥណពន្ធនៃគណនីរំលស់អចលកម្មរូបីយោងលើការលក់ចេញ ការបោះបង់ចោល ការបាត់បង់ និងការផ្ទេរ ។

- ករណីដែលចំនួនទឹកប្រាក់រំលស់បូកបន្ត នៃអចលកម្មស្មើនឹងតម្លៃបញ្ចូល គឺត្រូវបញ្ឈប់ការធ្វើទាយជ្ជទានរំលស់ ។ ការជម្រះលុះត្រាតែអចលកម្មនោះ ឈប់ប្រើប្រាស់ ។

១៧ - គណនីអ្នកផ្គត់ផ្គង់ ទំនិញ សេវា ការងារ "លេខ ៤០១"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលត្រូវទូទាត់សងទៅអ្នកផ្គត់ផ្គង់ទំនិញ ផ្តល់សេវាកម្ម ការងារដោយយោងតាមអាណត្តិបើកប្រាក់ និងការបង្វែរមកពីប្រភពផ្សេងៗ ។

ការកត់ត្រា :

ឥណពន្ធ :- កត់ត្រាចំនួនទឹកប្រាក់ដែលបានបើកផ្តល់ជូនអត្ថគាហកៈ

- កត់ត្រាចំនួនទឹកប្រាក់ដែលបានកាត់ទុកទូទាត់ទៅមុខសញ្ញាផ្សេង

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលត្រូវសងទៅអ្នកផ្គត់ផ្គង់ទំនិញ សេវា ការងារតាមអាណត្តិបើកប្រាក់ ឬបង្វែរពីគណនីផ្សេងមក

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ដែលត្រូវសងទៅអ្នកផ្គត់ផ្គង់ ។

ចំណាំ : គណនីលេខ ៤០១ ត្រូវតាមដានលម្អិតទៅតាមអ្នកផ្គត់ផ្គង់នីមួយៗ ។

១៨ - គណនី អ្នកផ្គត់ផ្គង់អចលកម្ម "លេខ ៤០៤"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលត្រូវទូទាត់សងទៅអ្នកផ្គត់ផ្គង់អចលកម្ម ដោយយោងតាមអាណត្តិបើកប្រាក់ ឬលិខិតផ្សេងទៀតដែលមានតម្លៃប្រហាក់ប្រហែល ។

ការកត់ត្រា :
ឥណពន្ធ :- កត់ត្រាចំនួនទឹកប្រាក់ដែលបានបើកផ្តល់ជូនអត្ថគាហក
- កត់ត្រាចំនួនទឹកប្រាក់ដែលបានកាត់ទុកទូទាត់ទៅមុខសញ្ញាផ្សេង
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលត្រូវសងទៅអ្នកផ្គត់ផ្គង់អចលកម្ម តាមអាណត្តិបើកប្រាក់ ឬលិខិតដែលមានតម្លៃប្រហាក់ប្រហែល ឬបង្វែរពីគណនីផ្សេងមក
សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់បំណុលដែលត្រូវសងទៅអ្នកផ្គត់ផ្គង់ ។
ចំណាំ : គណនីលេខ ៤០៤ ត្រូវតាមដានលម្អិតទៅតាមអ្នកផ្គត់ផ្គង់នីមួយៗ ។

១៩ - គណនី ការកាត់ទុក ការបំនាស់ "លេខ ៤០៧"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានកាត់ទុកពីចំនួនទឹកប្រាក់ត្រូវសងទៅអ្នកផ្គត់ផ្គង់ មន្ត្រីរាជការ បុគ្គលិក សម្រាប់សងទៅមុខសញ្ញាផ្សេងៗ យោងតាមការសម្រេចរបស់តុលាការ ឬអាជ្ញាធរដែលមានសមត្ថកិច្ច ។
ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ ដែលបានសងទៅអ្នកទទួលផល ពីការកាត់ទុកក្រោមរូបភាពជាសាច់ប្រាក់ បង្វែរ ឬជាមូលប្បទានប័ត្រ
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបានកាត់ចេញពីចំនួនទឹកប្រាក់ដែលត្រូវទូទាត់ជូនទៅអ្នកផ្គត់ផ្គង់ មន្ត្រីរាជការ បុគ្គលិក
សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ដែលបានកាត់ទុក ហើយពុំទាន់បានសងទៅអ្នកទទួលផលពីការកាត់ទុក ។
ចំណាំ : គណនីលេខ ៤០៧ ត្រូវតាមដានលម្អិតទៅតាមអ្នកទទួលផលពីការកាត់ទុក ។

២០ - គណនី អ្នកផ្គត់ផ្គង់ ឥណាយិក "លេខ ៤០៩"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានបើកផ្តល់មុនទៅអ្នកផ្គត់ផ្គង់ សម្ភារៈ សេវា និងទំនិញ ។ គណនីនេះត្រូវទូទាត់កាត់កងជាមួយនឹងគណនីអ្នកផ្គត់ផ្គង់នៅពេលមានអាណត្តិបើកប្រាក់ត្រូវទូទាត់ទៅអ្នកទាំងនោះ ។
ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ ដែលបានផ្តល់មុនជូនទៅអ្នកផ្គត់ផ្គង់ជាសាច់ប្រាក់ ជាមូលប្បទានប័ត្រ ឬដោយបង្វែរ
ឥណទាន :- កត់ត្រាចំនួនទឹកប្រាក់ ដែលបានកាត់កងជាមួយនឹងចំនួនទឹកប្រាក់ ដែលត្រូវសងទៅអ្នកផ្គត់ផ្គង់
- កត់ត្រាចំនួនទឹកប្រាក់ដែលអ្នកផ្គត់ផ្គង់បានបង្វិលសងមកវិញ
សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ត្រូវទារពីអ្នកផ្គត់ផ្គង់ ។
ចំណាំ :- គណនីលេខ ៤០៩ ពុំមានគំរូហត្ថលេខារបស់ម្ចាស់គណនីទេ គឺជាប្រភេទគណនីរង់ចាំ ។
- គណនីនេះត្រូវតាមដានលម្អិតទៅតាមអ្នកផ្គត់ផ្គង់ ។

២១ - គណនី ប្រាក់បៀវត្ស និងលាភការត្រូវសង "លេខ ៤២១"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់បៀវត្សលាភការ រង្វាន់ ប្រាក់វិភាជន៍សង្គម និងប្រាក់បំណាច់ផ្សេងៗ ដែលត្រូវសងទៅក្រុមប្រឹក្សាភិបាល បុគ្គលិកក្របខណ្ឌអចិន្ត្រៃយ៍ និងបុគ្គលិកមិនមែនក្របខណ្ឌ យោងតាមអាណត្តិបើកប្រាក់ ។
ការកត់ត្រា :
ឥណពន្ធ :- កត់ត្រាចំនួនទឹកប្រាក់បៀវត្សនិងលាភការដែលបានសង
- កត់ត្រាចំនួនទឹកប្រាក់បៀវត្សនិងលាភការដែលបានកាត់ទុកត្រូវសងទៅមុខសញ្ញាផ្សេង
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បៀវត្សនិងលាភការដែលត្រូវសង
សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់បៀវត្សនិងលាភការដែលពុំទាន់បានបើកផ្តល់ ។
ចំណាំ : គណនីលេខ ៤២១ មានគំរូហត្ថលេខារបស់ម្ចាស់គណនីដែលជាភ្នាក់ងារបើកផ្តល់ ។

២២ - គណនី សោហ៊ុយបេសកកម្ម និងសោហ៊ុយផ្សេងៗត្រូវសង "លេខ ៤២២"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ សោហ៊ុយបេសកកម្ម និងសោហ៊ុយផ្សេងៗដែលត្រូវសងទៅក្រុមប្រឹក្សាភិបាល បុគ្គលិកក្របខណ្ឌអចិន្ត្រៃយ៍ និងបុគ្គលិក មិនមែនក្របខណ្ឌតាមរយៈរដ្ឋទេយ្យករបុរេប្រទាន ។
ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់សោហ៊ុយបេសកកម្ម និងសោហ៊ុយផ្សេងៗ ដែលបានបើកផ្តល់ជាសាច់ប្រាក់ មូលប្បទានប័ត្រ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់សោហ៊ុយបេសកកម្ម និងសោហ៊ុយផ្សេងៗដែលត្រូវបើកផ្តល់
សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់សោហ៊ុយបេសកកម្ម និងសោហ៊ុយផ្សេងៗ ដែលត្រូវសង ។
ចំណាំ : គណនីលេខ ៤២២ ពុំចាំបាច់មានគំរូហត្ថលេខារបស់ម្ចាស់គណនីទេ ។

២៣ - គណនី ប្រាក់តម្កល់ធានាលើទីផ្សារសាធារណៈ "លេខ ៤៦២"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលអ្នកផ្គត់ផ្គង់ អ្នកម៉ៅការ បានបង់សម្រាប់តម្កល់ធានាលើការដេញថ្លៃ និងការអនុវត្តន៍កិច្ចសន្យា ។

ការកត់ត្រា :
ឥណពន្ធ :- កត់ត្រាចំនួនទឹកប្រាក់តម្កល់ធានាដែលសងជាសាច់ប្រាក់ មូលប្បទានប័ត្រ ឬបង្វែរ
- កត់ត្រាចំនួនទឹកប្រាក់តម្កល់ធានា ដែលបានបង្វែរចូលថវិការបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលពីប្រាក់តម្កល់ធានាដែលបានទទួលជាសាច់ប្រាក់ មូលប្បទានប័ត្រ ឬបង្វែរ
សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់តម្កល់ធានាដែលត្រូវសង ។
ចំណាំ : គណនីនេះត្រូវចែកទៅជាអនុគណនីទៅតាមអ្នកដេញថ្លៃនីមួយៗ ។

២៤ - គណនី ឥណាយិកផ្សេងៗ "លេខ ៤៦៣"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ត្រូវទារ ឬត្រូវដោះស្រាយផ្សេងៗ ។

ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ផ្សេងៗត្រូវទារ ឬត្រូវដោះស្រាយ
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ផ្សេងៗដែលបានដោះស្រាយ
សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ផ្សេងៗត្រូវទារ ឬត្រូវដោះស្រាយ ។
ចំណាំ :- គណនីលេខ ៤៦៣ ត្រូវសូន្យសមតុល្យនៅដំណាច់ឆ្នាំនីមួយៗ ។
- គណនីនេះ ជាប្រភេទគណនីរង់ចាំ ។

២៥ - គណនី ឥណទាយីផ្សេងៗ "លេខ ៤៦៥"

អនុគណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ត្រូវសងផ្សេងៗ ក្រៅពីបំណុលត្រូវសងទៅឱ្យអ្នកផ្គត់ផ្គង់ ក្រសួង មន្ទីរ អង្គភាព និងចំនួនទឹកប្រាក់ត្រូវដោះស្រាយ ។ គណនីលេខ ៤៦៥ ជាប្រភេទគណនីចម្លង ។

ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ផ្សេងៗបានសង ឬបានដោះស្រាយ
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ផ្សេងៗត្រូវសង ឬត្រូវដោះស្រាយ
សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ផ្សេងៗត្រូវសង ឬត្រូវដោះស្រាយ ។

២៦ - អនុគណនី ចំណូលផ្សេងៗ និងបង្វែររង់ចាំដោះស្រាយ "លេខ ៤៧០.៨"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលផ្សេងៗ ឬចំនួនទឹកប្រាក់ដែលត្រូវបង្វែរទៅគណនីអកម្មផ្សេងទៀត ។ អនុគណនីលេខ ៤៧០.៨ ស្ថិតនៅក្នុងគណនីចំណូលត្រូវនិយ័តភាព ។

ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលផ្សេងៗ និងបង្វែរបានដោះស្រាយ
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលផ្សេងៗ និងបង្វែររង់ចាំដោះស្រាយ
សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលរង់ចាំការបង្វែរ និងការដោះស្រាយ ។

២៧ - អនុគណនី ចំណាយផ្សេងៗរង់ចាំការដោះស្រាយ "លេខ ៤៧២.៨"

អនុគណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយ ឬមានលក្ខណៈប្រហាក់ប្រហែលដែលរង់ចាំការដោះស្រាយ ឬផ្ទេរទៅគណនីសកម្មផ្សេងទៀត ។ គណនីលេខ ៤៧២.៨ ស្ថិតនៅក្នុងគណនីចំណាយរងចាំនិយ័តកម្ម (លេខ ៤៧២) និងជាប្រភេទគណនីរង់ចាំ ។

ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយរង់ចាំការដោះស្រាយ
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយបានដោះស្រាយ
សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយរង់ចាំការដោះស្រាយ ។
ចំណាំ : អនុគណនីលេខ ៤៧២.៨ ត្រូវចែកជាអនុគណនីរងសម្រាប់មុខសញ្ញានីមួយៗ ។

២៨ - គណនី ចំណាយជាបណ្ដោះអាសន្ន (បុរេប្រទានសាច់ប្រាក់) សម្រាប់ដំណើរការ " លេខ ៤៧៣ "

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយជាបណ្ដោះអាសន្នលើការផ្តល់ប្រាក់បុរេប្រទាន ទៅមន្ត្រីរាជការដោយយោងតាមលិខិតសម្រេចរបស់នាយកបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានផ្តល់បុរេប្រទាន

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបានទូទាត់បុរេប្រទានដោយអាណត្តិបើកប្រាក់ ឬជាសាច់ប្រាក់

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បុរេប្រទានដែលពុំទាន់បានទូទាត់។

ចំណាំ :- គណនីលេខ ៤៧៣ ត្រូវតាមដានលម្អិតទៅតាមអ្នកទទួលប្រាក់បុរេប្រទាននីមួយៗ

-គណនីនេះត្រូវសូន្យសមតុល្យនៅដំណាច់ឆ្នាំ ។

២៩ - គណនី ចំណូលបានទទួលពុំទាន់មានសលាកបត្រ " លេខ ៤៧៤ "

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលហើយនៅរង់ចាំសលាកប័ត្របង់ជាចំណូលថវិកា ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានបង្វែរចូលថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលរង់ចាំសលាកប័ត្រ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់រង់ចាំការបង្វែរចូលថវិកា ។

ចំណាំ : គណនីនេះត្រូវសូន្យសមតុល្យ នៅដំណាច់ឆ្នាំ ។

៣០ - គណនី ចន្លោះប្រាក់រៀលនៅធនាគារជាតិ នៃកម្ពុជា និងនៅសាខា " លេខ ៥១០ "

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសំរាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលចំណាយជាប្រាក់រៀល ដែលកើតមាននៅធនាគារជាតិ នៃកម្ពុជា និងនៅសាខារាជធានី ខេត្ត ។ គណនីលេខ ៥១០ ឆ្លុះបញ្ចាំងប្រតិបត្តិការបញ្ជ្រាស នឹងគណនីនៅធនាគារជាតិ នៃកម្ពុជា និងនៅសាខារាជធានី ខេត្ត។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានបង់ជាសាច់ប្រាក់ដោយបង្វែរ និងបានពីការទូទាត់របស់សភាផាត់ទាត់ ជាមួយមូលប្បទានប័ត្រដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយពីធនាគារជាសាច់ប្រាក់ដោយបង្វែរ និងការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានប័ត្រដែលបានបោះផ្សាយ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើរបស់រតនាគារដែលកំពុងមាននៅធនាគារជាតិនៃកម្ពុជានិងសាខា។

ចំណាំ : គណនីលេខ ៥១០ ត្រូវចែកជាអនុគណនីប្រើនៅធនាគារជាតិ នៃកម្ពុជា និងប្រើនៅសាខាធនាគារជាតិ នៃកម្ពុជា ។

៣១ - គណនី មូលប្បទានប័ត្រធ្វើបេឡានិច្ច័យ " លេខ ៥១១ "

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់នៃមូលប្បទានប័ត្រដែលបានទទួល ហើយរង់ចាំការទូទាត់របស់សភាផាត់ទាត់ឬធនាគារ ។ គណនីនេះត្រូវសូន្យសមតុល្យ នៅដំណាច់ឆ្នាំ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ នៃមូលប្បទានប័ត្រ ដែលរតនាគារបានទទួល និងរង់ចាំការទូទាត់របស់សភាផាត់ទាត់ ឬធនាគារ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ នៃមូលប្បទានប័ត្រដែលបានទូទាត់

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ នៃមូលប្បទានប័ត្រដែលបានទទួល តែពុំទាន់បានទូទាត់ ។

៣២ - គណនី មូលប្បទានប័ត្របានបោះផ្សាយ " លេខ ៥១២ "

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់នៃមូលប្បទានប័ត្រដែលបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល បានបោះផ្សាយជូនទៅអត្ថគាហកហើយរង់ចាំការទូទាត់របស់សភាផាត់ទាត់ ឬធនាគារ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់នៃមូលប្បទានប័ត្រដែលបោះផ្សាយដោយបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ហើយបានទូទាត់ដោយសភាផាត់ទាត់ ឬធនាគារ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់នៃមូលប្បទានប័ត្រ ដែលបានបោះផ្សាយដោយបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ដែលរង់ចាំការទូទាត់

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់នៃមូលប្បទានប័ត្រដែលបានបោះផ្សាយដោយបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ដែលពុំទាន់បានទូទាត់ ។

៣៣ - គណនី ប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈ នៅរតនាគារ "លេខ ៥១៥"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល-ចំណាយ របស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលដែលផ្ញើនៅរតនាគារ ។ ចំនួនទឹកប្រាក់ដែលកត់ត្រាទៅក្នុងគណនីនេះ គឺមានទំនាក់ទំនងជាមួយនឹងចំណូល- ចំណាយដែលជាប្រតិបត្តិការថវិកា និងប្រតិបត្តិការរតនៈវត្ថុ ។ គណនីលេខ ៥១៥ ប្រើសម្រាប់កត់ត្រាក្នុងកិច្ចបញ្ជិកាគណនេយ្យថវិកា របស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើរបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលកំពុងមាន នៅរតនាគារ ។

<u>ចំណាំ</u> : គណនីលេខ ៥១៥ ឆ្លុះបញ្ចាំងប្រតិបត្តិការបញ្ច្រាស នឹងគណនីប្រាក់បញ្ញើថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលកត់ត្រានៅក្នុងកិច្ចបញ្ជិកាគណនេយ្យរដ្ឋនៅរតនាគារ ។

៣៤ - គណនី ចរន្តនៅធនាគារពាណិជ្ជ និងនៅសាខា "លេខ ៥១៧"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលចំណាយ ដែលកើតមាននៅធនាគារពាណិជ្ជ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូល ដែលបានបង់ជាសាច់ប្រាក់ដោយបង្វែរ និងបានពីការទូទាត់របស់សភាផាត់ទាត់ ជាមួយមូលប្បទានប័ត្រដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយពីធនាគារជាសាច់ប្រាក់ដោយបង្វែរ និងការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានប័ត្រ ដែលបានបោះផ្សាយ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើរបស់រតនាគារដែលកំពុងមាននៅធនាគារពាណិជ្ជ ។

<u>ចំណាំ</u> : គណនីនេះមានប្រតិបត្តិការបញ្ច្រាស នឹងគណនីនៅធនាគារពាណិជ្ជ ។

៣៥ - គណនី បុរេប្រទានត្រូវសង "លេខ ៥១៩"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់បុរេប្រទាន ដែលបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល បានទទួលពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬក្រសួងជាអាណាព្យាបាល ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល បានទូទាត់បុរេប្រទាន

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល បានទទួលបុរេប្រទាន (ត្រូវសង) ។

សមតុល្យ : ឥណទាយី បង្ហាញអំពីចំនួនទឹកប្រាក់បុរេប្រទានដែលបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ត្រូវសង ។

៣៦ - គណនី បេឡាសាច់ប្រាក់ "លេខ ៥៣២"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនសាច់ប្រាក់ចំណូល-ចំណាយបេឡាប្រចាំថ្ងៃ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនសាច់ប្រាក់ដែលបានបង់ចូលបេឡា

ឥណទាន : កត់ត្រាចំនួនសាច់ប្រាក់ដែលបានចំណាយពីបេឡា

សមតុល្យ : ឥណាយិក បង្ហាញចំនួនសាច់ប្រាក់ដែលមាននៅក្នុងបេឡា ។

៣៧ - គណនី រដ្ឋទេយ្យករបុរេប្រទាន "លេខ ៥៤៣"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់រដ្ឋទេយ្យបុរេប្រទាន ដែលរដ្ឋទេយ្យករបុរេប្រទានបានទទួលពីបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ទុកសម្រាប់ចំណាយ ។

ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ ដែលបានបើកផ្តល់ទៅរដ្ឋទេយ្យករបុរេប្រទានជាសាច់ប្រាក់ឬមូលប្បទានប័ត្រ
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលរដ្ឋទេយ្យករបុរេប្រទានបានទូទាត់ជាអាណត្តិបើកប្រាក់ ឬបានបង់ជាសាច់ប្រាក់ ចូលបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលវិញ
សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ដែលរដ្ឋទេយ្យករបុរេប្រទានពុំទាន់បានទូទាត់ជាមួយបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ។
<u>ចំណាំ</u> :-ការគណនាការបង្កើន ឬការបន្ថយកំរិតកំណត់រដ្ឋទេយ្យបុរេប្រទាន ថវិកាមិនមែនកម្មវិធី គឺធ្វើនៅក្រៅកិច្ចបញ្ជិកាគណនេយ្យ ។
-គណនីលេខ ៥៤៣ ត្រូវមានគំរូហត្ថលេខារបស់រដ្ឋទេយ្យករបុរេប្រទាន ។
-គណនីនេះ ត្រូវស្មូន្យសមតុល្យនៅដំណាច់ឆ្នាំ ។

៣៨ - គណនី សម្ភារៈផ្គត់ផ្គង់ ថែទាំ "លេខ ៦០១"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការទិញសម្ភារៈផ្គត់ផ្គង់ថែទាំ ។
ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ
សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។
<u>ចំណាំ</u> : គណនីលេខ ៦០១ ត្រូវចែកទៅជាអនុគណនីសម្រាប់ចំណាយទិញសម្ភារៈផ្គត់ផ្គង់សំអាត និងអនាម័យ សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំអគារ សម្ភារៈផ្គត់ផ្គង់ថែទាំសម្ភារៈឧបករណ៍ និង ប្រេងឥន្ធនៈនិងប្រេងរំអិល ។

៣៩ - គណនី សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល "លេខ ៦០២"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការទិញសម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល ។
ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ
សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។
<u>ចំណាំ</u> : គណនីលេខ ៦០២ ត្រូវចែកទៅជាអនុគណនី សម្រាប់ចំណាយទិញសម្ភារៈការិយាល័យនិងការបោះពុម្ព សៀវភៅមើលនិងឯកសារ និងសម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាលផ្សេងៗ ។

៤០ - គណនី សំលៀកបំពាក់និងការតុបតែង "លេខ ៦០៤"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការទិញសំលៀកបំពាក់ និងការតុបតែងលម្អ ។
ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ
សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។
<u>ចំណាំ</u> : គណនីលេខ ៦០៤ ត្រូវចែកទៅជាអនុគណនីសម្រាប់ចំណាយទិញឯកសណ្ឋាន និងសំលៀកបំពាក់និងការតុបតែងផ្សេងៗ ។

៤១ - គណនី សម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារ "លេខ ៦០៥"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការទិញសម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារ ។
ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ
សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

ចំណាំ : គណនីលេខ ៦០៥ ត្រូវចែកទៅជាអនុគណនីសម្រាប់ចំណាយទិញសម្ភារៈ និងបរិក្ខារបច្ចេកទេស សង្ហារឹម សម្ភារៈប្រើប្រាស់ សម្ភារៈនិងឧបករណ៍ដឹកជញ្ជូន និងសម្ភារៈបរិក្ខារផ្សេងៗ ។

៤២ - គណនី ថាមពល និងទឹក "លេខ ៦០៦"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការទិញ ទូទាត់ការប្រើប្រាស់ថាមពល និងទឹក ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

ចំណាំ : គណនីលេខ ៦០៦ ត្រូវចែកទៅជាអនុគណនីសម្រាប់ចំណាយលើអគ្គិសនី ចំណាយលើថ្លៃទឹក និងចំណាយលើការទិញថាមពលផ្សេងៗ ។

៤៣ - គណនី សម្ភារៈផ្គត់ផ្គង់ផ្សេងៗ "លេខ ៦០៨"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការទិញសម្ភារៈផ្គត់ផ្គង់ផ្សេងៗទៀត ដែលពុំបានរៀបរាប់ខាងលើក្នុងជំពូក ៦០ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

៤៤ - គណនី ការជួលមធ្យោបាយដឹកជញ្ជូន "លេខ ៦១២"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការទូទាត់ថ្លៃឈ្នួលមធ្យោបាយដឹកជញ្ជូន ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

៤៥ - គណនី ថ្លៃឈ្នួល និងបន្ទុក (អសង្ហារឹម) "លេខ ៦១៣"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការទូទាត់ថ្លៃឈ្នួលទីតាំងស្នាក់ការរដ្ឋបាល ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

៤៦ - គណនី សោហ៊ុយបណ្តុះបណ្តាលបុគ្គលិកក្នុង និងក្រៅប្រទេស "លេខ ៦១៤"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការបណ្តុះបណ្តាលបុគ្គលិកក្នុងនិងក្រៅប្រទេស ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

៤៧ - គណនី ការថែទាំ និងជួសជុល "លេខ ៦១៥"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការថែទាំនិងជួសជុល ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ
សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។
ចំណាំ : គណនីលេខ ៦១៥ ត្រូវចែកទៅជាអនុគណនីសម្រាប់ចំណាយលើការថែទាំ និងជួសជុលអាគារ ការថែទាំនិងជួសជុលមធ្យោបាយដឹកជញ្ជូន និងការថែទាំនិងជួសជុលឧបករណ៍សម្ភារៈការិយាល័យ សម្ភារៈពត៌មានវិទ្យានិងទូរគមនាគមន៍ ។

៤៨ - គណនី សោហ៊ុយធានារ៉ាប់រង "លេខ ៦១៦"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការបង់សោហ៊ុយធានារ៉ាប់រងផ្សេងៗ ។

ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ
សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

៤៩ - គណនី សោហ៊ុយសិក្សាពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សេវា និងសោហ៊ុយនៃការប្រើប្រាស់សិទ្ធិ "លេខ ៦១៧"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការសិក្សាពិសោធន៍ សោហ៊ុយ នៃការប្រើប្រាស់សេវា និងសោហ៊ុយនៃការប្រើប្រាស់សិទ្ធិ ។

ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ
សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។
ចំណាំ : គណនីលេខ ៦១៧ ត្រូវចែកទៅជាអនុគណនីសម្រាប់ចំណាយលើសោហ៊ុយសិក្សាពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សេវា និងសោហ៊ុយនៃការប្រើប្រាស់សិទ្ធិ ។

៥០ - គណនី បុគ្គលិកខាងក្រៅ "លេខ ៦២១"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការទូទាត់ប្រាក់កម្រៃ លាភការ របស់បុគ្គលិកខាងក្រៅ ដែលបានផ្តល់សេវាជូនបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ។

ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ
សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។
ចំណាំ : គណនីលេខ ៦២១ ត្រូវចែកទៅជាអនុគណនីសម្រាប់ចំណាយលើលាភការរបស់ភ្នាក់ងារជាតិជាប់កិច្ចសន្យា ភ្នាក់ងារបរទេសជាប់កិច្ចសន្យា និងលាភការរបស់បុគ្គលិកសមូហភាពផ្សេងៗ ។

៥១ - គណនី ទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយ "លេខ ៦២២"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើទំនាក់ទំនងសាធារណៈ និងការផ្សព្វផ្សាយ ។

ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ
សមតុល្យ : ឥណពន្ធបង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។
ចំណាំ : គណនីលេខ ៦២២ ត្រូវចែកទៅជាអនុគណនីសម្រាប់ចំណាយសោហ៊ុយទទួលភ្ញៀវជាតិ សោហ៊ុយទទួលភ្ញៀវបរទេស ប្រជុំសិក្ខាសាលានិងសន្និសីទ ចំណាយពិធីបុណ្យ ចំណាយសម្រាប់វត្ថុអនុស្សាវរីយ៍ក្នុងនិងក្រៅប្រទេស និងការឃោសនានិងផ្សព្វផ្សាយពត៌មានសាធារណៈ ។

៥២ - គណនី សោហ៊ុយឯកសារព័ត៌មាន និងឯកសារ "លេខ ៦២៣"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការទូទាត់ថ្លៃជាវសារព័ត៌មាន និងទិញឯកសារ ។

ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ
សមតុល្យ : ឥណពិកបង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

៥៣ - គណនី ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស "លេខ ៦២៤"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការទូទាត់សោហ៊ុយធ្វើដំណើរ ប្រាក់បេសកកម្ម និងសោហ៊ុយស្នាក់នៅក្នុងប្រទេស ។

ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ
សមតុល្យ : ឥណពិកបង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។
ចំណាំ : គណនីលេខ ៦២៤ ត្រូវចែកទៅជាអនុគណនីសម្រាប់សោហ៊ុយដឹកជញ្ជូន សោហ៊ុយបេសកកម្ម និងសោហ៊ុយស្នាក់នៅ ។

៥៤ - គណនី ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស "លេខ ៦២៥"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការទូទាត់សោហ៊ុយធ្វើដំណើរ ប្រាក់បេសកកម្ម និងសោហ៊ុយស្នាក់នៅក្រៅប្រទេស។

ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ
សមតុល្យ : ឥណពិកបង្ហាញពីចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។
ចំណាំ : គណនីលេខ ៦២៥ ត្រូវចែកទៅជាអនុគណនីសម្រាប់សោហ៊ុយដឹកជញ្ជូន សោហ៊ុយបេសកកម្ម និងសោហ៊ុយស្នាក់នៅ ។

៥៥ - គណនី សោហ៊ុយប្រៃសណីយ៍ និងទូរគមនាគមន៍ "លេខ ៦២៦"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការទូទាត់សេវាប្រៃសណីយ៍ និងទូរគមនាគមន៍ ។

ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ
សមតុល្យ : ឥណពិកបង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។
ចំណាំ : គណនីលេខ៦២៦ត្រូវចែកទៅជាអនុគណនីសម្រាប់សោហ៊ុយប្រៃសណីយ៍ និងសោហ៊ុយទូរគមនាគមន៍។

៥៦ - គណនី សោហ៊ុយធនាគារ "លេខ ៦២៧"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើសេវារបស់ធនាគារ ។

ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ
សមតុល្យ : ឥណពិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

៥៧ - គណនី សេវាខាងក្រៅផ្សេងៗទៀត "លេខ ៦២៨"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើសេវាខាងក្រៅផ្សេងៗទៀត ដែលពុំបានរៀបរាប់ក្នុងគណនីលេខ ៦២១ ដល់គណនីលេខ ៦២៧ ក្នុងជំពូកលេខ ៦២ ។

ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

៥៨ - គណនី លតាបត្រ "លេខ ៦៣១"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការទិញលតាបត្រ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិកបង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

៥៩ - គណនី ពន្ធ និងអាករផ្សេងទៀត "លេខ ៦៣៨"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើបន្ទុកពន្ធ និងអាករផ្សេងទៀត ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិកបង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

៦០ - គណនីរង្វាន់ និងប្រាក់បំណាច់ផ្សេងៗ "លេខ ៦៤៣"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើប្រាក់រង្វាន់ និងប្រាក់បំណាច់ផ្សេងៗ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិកបង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

<u>ចំណាំ</u> : គណនីលេខ ៦៤៣ មានអនុគណនីសម្រាប់ប្រាក់រង្វាន់ និងប្រាក់បំណាច់ផ្សេងៗ ។

៦១ - គណនី លាភការ និងប្រាក់បំណាច់បុគ្គលិកមិនមែនក្របខ័ណ្ឌ "លេខ ៦៤៤"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកា លើលាភការ និងប្រាក់បំណាច់បុគ្គលិកមិនមែនក្របខ័ណ្ឌ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិកបង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

<u>ចំណាំ</u> : គណនីលេខ ៦៤៤ ត្រូវចែកទៅជាអនុគណនីសម្រាប់បៀវត្សមូលដ្ឋានបុគ្គលិកជាប់កិច្ចសន្យា និងលាភការផ្សេងៗទៀតបុគ្គលិកជាប់កិច្ចសន្យា ។

៦២ - គណនី ប្រាក់វិភាជន៍សង្គម "លេខ ៦៤៥"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើប្រាក់វិភាជន៍សង្គមសម្រាប់បុគ្គលិក មន្ត្រីរាជការ របស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

<u>ចំណាំ</u> : គណនីលេខ ៦៤៥ ត្រូវចែកជាអនុគណនីសម្រាប់ប្រាក់បំណាច់ជាលក្ខណៈគ្រួសារ មន្ត្រីមានជំងឺនិងឧបត្ថម្ភអ្នកសម្រាលកូន ឧបត្ថម្ភគ្រោះថ្នាក់ក្នុងការងារនិងទព្វលភាព និងប្រាក់វិភាជន៍សង្គមផ្សេងៗ។

៦៣ - គណនី ឧបត្ថម្ភធនដល់អង្គការសាធារណៈ "លេខ ៦៥២"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការផ្តល់ឧបត្ថម្ភធនដល់អង្គការសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌។ល។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

៦៤ - គណនី ឧបត្ថម្ភធនដល់អង្គភាពដែលមានលក្ខណៈសង្គម និង វប្បធម៌ "លេខ ៦៥៨"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការផ្តល់ឧបត្ថម្ភធនដល់អង្គភាពដែលមានលក្ខណៈសង្គម និងវប្បធម៌ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

<u>ចំណាំ</u> : គណនីលេខ ៦៥៨ មានអនុគណនីសម្រាប់ការផ្តល់ឧបត្ថម្ភធនដល់កាកបាទក្រហម ។

៦៥ - គណនី ខាតពីការប្តូរប្រាក់ "លេខ ៦៦៦"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានចាត់ជាចំណាយថវិកាលើការខាតពីការប្តូរប្រាក់។ លំអៀងពីការប្តូរប្រាក់គឺបានពីការប្រៀបធៀបរវាងចំនួនទឹកប្រាក់ជារៀល ដែលបានកត់ត្រាកន្លងមក និងចំនួនទឹកប្រាក់ជារៀល ដែលបានពីការគណនាជាថ្មីដោយយកចំនួនទឹកប្រាក់រូបិយបណ្ណបរទេសគុណនឹងអត្រាប្តូរប្រាក់របស់ធនាគារជាតិ នៃកម្ពុជា នៅថ្ងៃដែលគណនារកប្រាក់លំអៀងនេះ ។ ការកត់ត្រាទៅក្នុងគណនីនេះជាប្រតិបត្តិការ ថវិកាតាមដីកាដោយពុំចាំបាច់មានអាណត្តិបើកប្រាក់ និងឥណទានថវិកា ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចាត់ទុកជាចំណាយថវិកា

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

៦៦ - គណនី បន្ទុកហិរញ្ញវត្ថុផ្សេងៗទៀត "លេខ ៦៦៨"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើបន្ទុកហិរញ្ញវត្ថុផ្សេងៗទៀត ដែលពុំបានរៀបរាប់ខាងលើក្នុងជំពូក ៦៦ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

៦៧ - គណនី តម្លៃគណនេយ្យ នៃចំណែកសកម្មបានលក់ (តម្លៃនៅសល់) "លេខ ៦៧៥"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើតម្លៃ នៃទ្រព្យសកម្មនៅសល់ដែលមិនទាន់បានគិតរំលស់អស់ ។ តម្លៃនៅសល់បានពីបរិយាទាន ដកទឹកប្រាក់រំលស់បូកបន្តកន្លងមក ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចាត់ជាចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ

សមតុល្យ : ឥណពន្ធបង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

<u>ចំណាំ</u> : ការកត់ត្រាប្រតិបត្តិការនេះ គឺជាប្រតិបត្តិការតាមដីកាថវិកាដោយពុំចាំបាច់បោះផ្សាយអាណត្តិបើកប្រាក់។

៦៨ - គណនី ទាយជ្ជទានឱ្យដល់រំលស់អចលកម្មអរូបី "លេខ ៦៨១"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើទាយជ្ជទានឱ្យដល់រំលស់អចលកម្មអរូបី ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់រំលស់បានចាត់ជាចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលបានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិកបង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

ចំណាំ : ការកត់ត្រាប្រតិបត្តិការនេះគឺជាប្រតិបត្តិការតាមដីកាថវិកា ដោយពុំចាំបាច់បោះផ្សាយអាណត្តិបើកប្រាក់។

៦៩ - គណនី ឆាយជូទានឱ្យដល់រំលស់អចលកម្មរូបី "លេខ ៦៨២"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើទាយជូទានឱ្យដល់រំលស់អចលកម្មរូបី ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់រំលស់បានចាត់ជាចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

ចំណាំ : ការកត់ត្រាប្រតិបត្តិការនេះគឺជាប្រតិបត្តិការតាមដីកាថវិកា ដោយពុំចាំបាច់បោះផ្សាយអាណត្តិបើកប្រាក់។

ទិដ្ឋានបន្ថែម:
- ការបង់សំណោះចំណាយនៅក្នុងឆ្នាំ: ត្រូវកត់ត្រាទឹកប្រាក់សំណោះចំណាយខាងផ្នែកឥណទាន នៃគណនីចំណាយថវិកាដែលពាក់ព័ន្ធ និងខាងផ្នែកឥណពន្ធ នៃគណនីហិរញ្ញវត្ថុ ។
- សំណោះចំណាយរបស់ឆ្នាំចាស់ដែលបានបង់នៅឆ្នាំថ្មី : ត្រូវកត់ត្រាទឹកប្រាក់សំណោះចំណាយខាងផ្នែកឥណទាន នៃគណនីចំណូលថវិកាផលហិរញ្ញវត្ថុផ្សេងទៀត និងខាងផ្នែកឥណពន្ធនៃគណនីហិរញ្ញវត្ថុ ។
- ចំពោះការបន្ថយចំណាយថវិកាដែលបានកត់ត្រាភ័ន្តច្រលំ : ត្រូវកត់ត្រាចំនួនទឹកប្រាក់ដែលត្រូវបន្ថយនៅខាងឥណទាន នៃគណនីចំណាយថវិកាដែលពាក់ព័ន្ធ ។

៧០ - គណនី ឧបត្ថម្ភកធនពីទ្វេភាគី "លេខ ៧៥១"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានមកពីឧបត្ថម្ភកធនពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេសក្នុងក្រមខណ្ឌទ្វេភាគី ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាពីឧបត្ថម្ភកធនដែលបានទទួល

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

៧១ - គណនី ឧបត្ថម្ភកធនពីពហុភាគី "លេខ ៧៥២"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកា ដែលបានមកពីឧបត្ថម្ភកធនពីដៃគូអភិវឌ្ឍន៍ដែលជាអង្គការអន្តរជាតិក្នុងក្រមខណ្ឌពហុភាគី ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាពីឧបត្ថម្ភកធនដែលបានទទួល

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

៧២ - គណនី ជំនួយផ្សេងៗទៀត "លេខ ៧៥៣"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានមកពីជំនួយ ឧបត្ថម្ភកធនផ្សេងៗទៀតដែលពុំបានរៀបរាប់នៅក្នុងជំពូក ៧៥ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាពីឧបត្ថម្ភកធនដែលបានទទួល

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

ចំណាំ : គណនីលេខ ៧៥៣ ចែកចេញជាអនុគណនីសម្រាប់ប្រាក់ឧបត្ថម្ភកធនពីថវិការដ្ឋសម្រាប់ដំណើរការប្រាក់ភាគទានពីរាជរដ្ឋាភិបាល ភាគទានពីមន្ត្រីរាជការស៊ីវិល ប្រាក់ឧបត្ថម្ភកធនពីក្រសួង ស.អ.យ. ពីមន្ទីរ ស.អ.យ. និងឧបត្ថម្ភកធននិងចំណូលស្របច្បាប់ផ្សេងទៀត ។

៧៣ - គណនី ចំណូលពីការប្រាក់ "លេខ ៧៦១"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានមកពីការប្រាក់នៃការឱ្យខ្ចី និងពីប្រាក់បញ្ញើនៅធនាគារ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានពីការប្រាក់

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

៧៤ - គណនី ចំណេញពីការប្តូរប្រាក់ "លេខ ៧៦៦"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានមកពីចំណេញពីការប្តូរប្រាក់ ។ លំអៀងពីការប្តូរប្រាក់គឺបានពីការប្រៀបធៀបរវាងចំនួនទឹកប្រាក់ជារៀល ដែលបានកត់ត្រាកន្លងមក និងចំនួនទឹកប្រាក់ជារៀល ដែលបានពីការគណនាជាថ្មីដោយយកចំនួនទឹកប្រាក់រូបិយបណ្ណបរទេសគុណនឹងអត្រាប្តូរប្រាក់របស់ធនាគារជាតិ នៃកម្ពុជា នៅថ្ងៃដែលគណនារកប្រាក់លំអៀងនេះ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានពីចំណេញពីការប្តូរប្រាក់

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

៧៥ - គណនី ផលហិរញ្ញវត្ថុផ្សេងទៀត "លេខ ៧៦៨"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានមកពីផលហិរញ្ញវត្ថុផ្សេងៗទៀតនៅក្នុងជំពូក ៧៦ ដែលពុំបានរៀបរាប់ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាពីផលហិរញ្ញវត្ថុដែលបានទទួលពីប្រភពផ្សេងៗ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

៧៦ - គណនី ផលពីការលក់អចលកម្ម "លេខ ៧៧៥"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានមកពីការលក់ចលកម្មអរូបី និងអចលកម្មរូបី ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានពីការលក់អចលកម្ម

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

៧៧ - គណនី ផលពិសេសផ្សេងៗទៀត "លេខ ៧៧៨"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានមកពីផលពិសេសផ្សេងៗទៀត នៅក្នុងជំពូក ៧៧ ដែលមិនបានរៀបរាប់ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានពីការលក់អចលកម្ម

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

ទិដ្ឋានបន្ថែម: ចំពោះការបន្ថយចំណូលថវិកាដែលពាក់ព័ន្ធនឹងជំពូក ៧០, ៧១, ៧២, ៧៣, ៧៤, ៧៥, ៧៦, និង ៧៧ គឺត្រូវកត់ត្រាខាងឥណពន្ធ នៃគណនីពាក់ព័ន្ធ ។